


ខេមបូចា CamboJA

សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា
Cambodian Journalists Alliance Association

# របាយការណ៍ ប្រចាំឆ្នាំ២០២៤

លើកកម្ពស់សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលបានព័ត៌មាន

## ទស្សនវិស័យរបស់យើង

ខេមបូចា មានទស្សនវិស័យថា មនុស្សគ្រប់រូប (ដែលរស់នៅក្នុងប្រទេសកម្ពុជា) រីករាយនឹងសិទ្ធិទទួលបានព័ត៌មាន និងសេរីភាពសារព័ត៌មាន។

## បេសកកម្មរបស់យើង

ខេមបូចា លើកកម្ពស់សេរីភាពសារព័ត៌មាន គាំទ្រនិងការពារអ្នកសារព័ត៌មាន ហើយផ្តល់ព័ត៌មានដែលអាចទុកចិត្តបាន។

## ប្រវត្តិរបស់យើង

ខេមបូចា ត្រូវបានបង្កើតឡើងដោយអ្នកសារព័ត៌មានឯករាជ្យមួយក្រុមមកពីស្ថាប័នសារព័ត៌មានផ្សេងៗ រួមទាំងស្ថាប័នដែលត្រូវបានបិទដោយការបង្ក្រាបរបស់រដ្ឋាភិបាលប្រឆាំងនឹងសារព័ត៌មានទាំងនោះក្នុងឆ្នាំ ២០១៧។ សមាគមនេះបានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃជាសមាគមអ្នកសារព័ត៌មាន។ ខេមបូចា តំណាងឱ្យអ្នកសារព័ត៌មានកម្ពុជាជាង ១០០ នាក់។

## គោលការណ៍ណែនាំរបស់យើង

គោលការណ៍ណែនាំរបស់យើងមានប្រភពចេញពីគោលការណ៍សិទ្ធិមនុស្សដែលត្រូវបានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ICCPR) និងកិច្ចព្រមព្រៀងពាក់ព័ន្ធ ព្រមទាំងរដ្ឋធម្មនុញ្ញ និងច្បាប់ ក៏ដូចជាបទប្បញ្ញត្តិពាក់ព័ន្ធរបស់ប្រទេសកម្ពុជា ជាពិសេសទាក់ទងនឹងសេរីភាពសារព័ត៌មាន។

# គុណតម្លៃរបស់យើង

សកម្មភាពរបស់យើងត្រូវបានអនុវត្តន៍ដោយយោងលើគុណតម្លៃចំនួនប្រាំ៖



# មាតិកា

សេចក្តីសង្ខេប ..... ៥

អន្តរាគមន៍របស់ខេមបូចា ..... ៩

ការរកឃើញសំខាន់ៗ ..... ៩

វត្ថុបំណងទី១៖ បង្កើនការគាំទ្រ និងការការពារអ្នកសារព័ត៌មាន ដែលប្រឈមនឹងហានិភ័យ និង/ឬ ការបៀតបៀន

វត្ថុបំណងទី២៖ តស៊ូមតិដើម្បីឱ្យមានបរិយាកាសនិងបទប្បញ្ញត្តិគាំទ្រប្រព័ន្ធ ផ្សព្វផ្សាយដែលអំណោយផលដល់វិស័យសារព័ត៌មាន

វត្ថុបំណងទី៣៖ បង្កើនភាពអាចរកបាន និងលទ្ធភាពទទួលបានព័ត៌មាន ដែលអាចទុកចិត្តបានសម្រាប់អ្នកទស្សនា

វត្ថុបំណងទី៤៖ ការអភិវឌ្ឍ និងការគ្រប់គ្រងអង្គភាព

បញ្ហាប្រឈម ..... ២៥

មេរៀនដែលទទួលបាន ..... ២៦

# សេចក្ដីសង្ខេប

ក្នុងអំឡុងពេលអនុវត្តយុទ្ធសាស្រ្ត (២០២៤-២០២៨) ខេមបូចា រំពឹងថានឹងសម្រេចបានលទ្ធផលកម្មវិធីសំខាន់ចំនួនបីៈ (១) បង្កើនការគាំទ្រ និងការការពារអ្នកសារព័ត៌មាន, (២) ធ្វើឱ្យប្រសើរឡើងនូវបរិយាកាសនិងគោលនយោបាយគាំទ្រប្រព័ន្ធផ្សព្វផ្សាយដែលអំណោយផលដល់វិស័យសារព័ត៌មាន, (៣) បង្កើនភាពអាចរកបាននិងលទ្ធភាពទទួលបានព័ត៌មានដែលអាចទុកចិត្តបាន។

ចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២៤ មានឧបទ្ទវហេតុយ៉ាងហោចណាស់ ៤១ ករណីត្រូវបានកត់ត្រា ដែលប៉ះពាល់ដល់អ្នកសារព័ត៌មានជាង ៦០ នាក់។ ក្នុងចំណោមករណីទាំងនេះ មានចំនួន ៦៨ ភាគរយពាក់ព័ន្ធនឹងសកម្មភាពផ្លូវច្បាប់។ ក្នុងចំណោមករណីជាច្រើន អ្នកសារព័ត៌មានត្រូវបានចោទប្រកាន់ពីបទញុះញង់ និងបរិហារកេរ្តិ៍ ដែលទាក់ទងនឹងការរាយការណ៍ប៉ះពាល់ដល់មុខមាត់ អាជ្ញាធរ និងបុគ្គលផ្សេងទៀត។ បទឧក្រិដ្ឋដូចជា ការញុះញង់ ការជំរិតទារប្រាក់ និងបរិហារកេរ្តិ៍ ត្រូវបានប្រើប្រាស់កាន់តែច្រើនប្រឆាំងនឹងអ្នកសារព័ត៌មាន ជាជាងការប្រើប្រាស់នីតិវិធីរដ្ឋប្បវេណីដូចដែលបានចែងក្នុងច្បាប់ស្តីពីរបបសារព័ត៌មាន។ករណីគួរឱ្យកត់សម្គាល់មួយគឺ ការចាប់ខ្លួនអ្នកសារព័ត៌មានជ័យលាភី លោក ម៉ិច ដារ៉ា ដែលមានឈ្មោះល្បីលើការរាយការណ៍យ៉ាងទំលំទូលាយរបស់លោកពីអំពើជួញដូរមនុស្ស និងប្រតិបត្តិការបោកបញ្ឆោតតាមប្រព័ន្ធបច្ចេកវិទ្យានៅកម្ពុជា។ លោកត្រូវបានចាប់ខ្លួននៅថ្ងៃទី៣០ ខែកញ្ញា ហើយត្រូវបានដាក់ឃុំខ្លួនបណ្តោះអាសន្ន ដោយចោទប្រកាន់ពីបទ «ញុះញង់បង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម» ដោយសារការបង្ហោះមួយលើបណ្តាញសង្គមរបស់លោក។ បន្ទាប់មក លោកត្រូវបានដោះលែងនៅថ្ងៃទី២៤ ខែតុលា បន្ទាប់ពីបានចេញវីដេអូសុំទោសជាសាធារណៈចំពោះថ្នាក់ដឹកនាំ។

បញ្ហាប្រឈមផ្សេងទៀតដែលបានជួបប្រទះក្នុងឆ្នាំ២០២៤រួមមានការចូលរួមតិចតួចពីអ្នកសារព័ត៌មានស្ត្រីនៅក្នុងវគ្គបណ្ដុះបណ្ដាលនិងអ្នកសារព័ត៌មានមូលដ្ឋានតាមតំបន់ក៏ដូចជាបញ្ហាប្រឈមក្នុងការទទួលបានប្រភពព័ត៌មានរសើបដែលជាអាទិ៍រួមមានប្រភពដែលទាក់ទងនឹងអំពើពុករលួយនិងការជួញដូរមនុស្សជាដើម។បរិបទផ្នែកមូលនិធិដែលកំពុងផ្លាស់ប្តូរ ក៏បានបង្កើនភាពស្មុគស្មាញដល់ប្រតិបត្តិការផងដែរ ចាប់ពីការដកហូតជំនួយភ្លាមៗពី SIDA រហូតដល់ការបង្កកជំនួយអភិវឌ្ឍន៍បរទេសរបស់សហរដ្ឋអាមេរិក នៅចុងខែមករា ឆ្នាំ២០២៥។ ក្រុមការងារឃ្លាំមើលសុវត្ថិភាពអ្នកសារព័ត៌មាន ក៏ជួបការលំបាកក្នុងការកំណត់ករណីបៀតបៀនអ្នកសារព័ត៌មានជាពិសេសនៅតំបន់ដាច់ស្រយាល ហើយពួកគេក៏ខ្វះចំណេះដឹងចាំបាច់សម្រាប់ស្រាវជ្រាវផងដែរ។ លើសពីនេះទៅទៀត ការសម្របខ្លួនរបស់បន្ទប់ព័ត៌មានខេមបូចា ទៅនឹងចំណង់ចំណូលចិត្តរបស់អ្នកអាន អ្នកស្តាប់ដែលកំពុងផ្លាស់ប្តូរ ក៏នៅមានកម្រិត ដែលនាំឱ្យមានតម្រូវការកសាងសមត្ថភាពបន្ថែមទៀតដល់អ្នកសារព័ត៌មានលើការផលិតមាតិកាប្រកបដោយភាពច្នៃប្រឌិតជាពិសេសសម្រាប់ប្រព័ន្ធផ្សព្វផ្សាយសង្គម។ ការរៀបចំយុទ្ធសាស្រ្តចូលរួមជាមួយអ្នកអាន អ្នកទស្សនា និងផលិតមាតិកា ត្រូវបានពន្យារពេល ប៉ុន្តែនៅតែជាអាទិភាពចម្បងសម្រាប់ឆ្នាំ ២០២៥។

ទោះបីជាមានបញ្ហាប្រឈមទាំងនេះក៏ដោយ ខេមបូចា ក៏នៅតែអាចសម្រេចបានលទ្ធផលសំខាន់ៗដូចខាងក្រោមនៅក្នុងឆ្នាំ ២០២៤នេះ។

## ខេមបូចាព័ត៌មាន

- ចំនួនអ្នកអានព័ត៌មានបានកើនឡើងគ្រប់វេទិកាទាំងអស់។ នៅលើគេហទំព័រព័ត៌មានភាសាអង់គ្លេស (cambojanews.com) ចំនួនអ្នកប្រើប្រាស់បានកើនឡើង ៣៧% ពី ៤០១,០៧៩ នាក់ក្នុងឆ្នាំ ២០២៣ ទៅដល់ ៦៣៨,០៤៥ នាក់ ក្នុងឆ្នាំ ២០២៤ ដែលលើសគោលដៅប្រចាំឆ្នាំ ១០%។ ខណៈដែល គេហទំព័រព័ត៌មានភាសាខ្មែរ (khmer.cambojanews.com) ក៏បានកើនឡើង ២៦% ពី ៦៥៨,៦០០ នាក់ក្នុងឆ្នាំ ២០២៣ ទៅដល់ ៨៩៣,៣៥៩ នាក់។
- នៅលើទំព័រហ្វេសប៊ុក ព័ត៌មានខេមបូចាជាភាសាខ្មែរ ចំនួនអ្នកតាមដានបានកើនពី ១៩,០១៤ នាក់ក្នុងឆ្នាំ ២០២៣ ទៅដល់ ២២,៥៣៤ នាក់ក្នុងឆ្នាំ ២០២៤ (កើនឡើង ១៦%)។ ចំនួនអ្នកតាមដានទំព័រហ្វេសប៊ុក ព័ត៌មានខេមបូចាភាសាអង់គ្លេស ក៏បានកើនពី ៩,០៦១ នាក់ក្នុងឆ្នាំ ២០២៣ ទៅដល់ ១០,០០២ នាក់ក្នុងឆ្នាំ ២០២៤ (កើនឡើង ៩%)។
- ព័ត៌មានរបស់យើង បានបន្ថែមសំឡេងឱ្យសហគមន៍ដែលងាយរងគ្រោះ និងរងគ្រោះ ហើយបាន រួមចំណែកនាំមកនូវការអភិវឌ្ឍជាវិជ្ជមាននៅកម្រិតមូលដ្ឋាន។ នៅឆ្នាំ ២០២៤ ខេមបូចា បានផលិតរឿងសរុបចំនួន ៧២២ (រួមមានអត្ថបទ៦៧០ វីដេអូ ៤៨ និងរូបថតជាសាច់រឿងពត៏មានចំនួន៤) ដែលផ្តោតលើប្រធានបទសំខាន់ៗ និងមានផលជះខ្លាំងដល់សហគមន៍ ដូចជាបញ្ហាសិទ្ធិមនុស្ស បរិស្ថាន ដីធ្លី និងពលកម្មជាដើម។

## ការស្រាវជ្រាវ និងតស៊ូមតិ

- សកម្មភាពតស៊ូមតិ និងវេទិកាជជែកពិភាក្សាជាច្រើនច្រើន ត្រូវបានធ្វើឡើងដើម្បីពង្រីកសំឡេងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ អ្នកសារព័ត៌មានស្រ្តី និងគុណតម្លៃសារព័ត៌មានផ្អែកលើការពិត ព្រមទាំងអំពាវនាវឱ្យអ្នកមានសិទ្ធិធ្វើសេចក្តីសម្រេចចិត្ត បង្កើតបរិយាកាសអំណោយផល និងការការពារសិទ្ធិសារព័ត៌មានសេរី។
- មនុស្សយ៉ាងហោចណាស់ ៥៩០ នាក់ (២៣០ នាក់ជាស្រ្តី ប្រមាណ៣៩%) ត្រូវបានកៀគរឱ្យចូលរួមក្នុងវេទិកាសាធារណៈ សិក្ខាសាលា និងសន្និសីទផ្សេងៗ ដូចជា ទិវាសេរីភាពសារព័ត៌មានពិភពលោក វេទិកាអ៊ីនធឺណិតភ្នំពេញ សន្និសីទជាតិស្តីពីទំនុកចិត្តលើសារព័ត៌មានកម្ពុជា និងព្រឹត្តិការណ៍ដាក់ឱ្យដំណើរការក្របខណ្ឌតាមដាន និងឃ្លាំមើលផ្អែកតាមផែនការសកម្មភាពរបស់អង្គការសហប្រជាជាតិស្តីពីសុវត្ថិភាពអ្នកសារព័ត៌មាន និងបញ្ហានិទ្ទណ្ឌភាព និងសូចនាករសុវត្ថិភាពអ្នកសារព័ត៌មានរបស់អង្គការយូណេស្កូ។
- អនុសាសន៍ចំនួន ១៧ ត្រូវបានដាក់ជូនក្រសួងនានា ដើម្បីអំពាវនាវស្នើឱ្យកែលម្អច្បាប់ និងបរិយាកាសការងាររបស់ប្រព័ន្ធផ្សព្វផ្សាយ តាមរយៈរបាយការណ៍ត្រួតពិនិត្យប្រចាំត្រីមាស និងប្រចាំឆ្នាំ ក៏ដូចជាសេចក្តីថ្លែងការណ៍នានារបស់ខេមបូចា ក្នុងឆ្នាំ ២០២៤។

- បញ្ជីអនុសាសន៍មួយក៏ត្រូវបានផ្ញើជូនក្រសួងព័ត៌មាន ដើម្បីបង្ហាញក្ដីកង្វល់ចំពោះ«ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន» ដែលក្រសួងបានដាក់ឱ្យប្រើប្រាស់។
- ទំព័រថ្មីមួយ (camboja.net/advocacy) ត្រូវបានដាក់ឱ្យដំណើរការនៅលើគេហទំព័រដែលមានស្រាប់របស់សមាគមដើម្បីផ្សព្វផ្សាយដំណឹងថ្មីៗនៃករណីរំខានយាយីប្រឆាំងនឹងប្រព័ន្ធផ្សព្វផ្សាយ របាយការណ៍លម្អិត ករណីសិក្សា និងយុទ្ធនាការតស៊ូមតិលើសុវត្ថិភាពអ្នកសារព័ត៌មាន សេរីភាពសារព័ត៌មាន ក៏ដូចជាការទទួលបានព័ត៌មាន។ ការចេញផ្សាយទិន្នន័យសុវត្ថិភាពរបស់អ្នកសារព័ត៌មានជាប្រចាំរបស់ខេមបូចា នៅលើគេហទំព័រខ្នាតតូចរបស់ខ្លួន (camboja.net/advocacy) និងវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គមបាននាំឱ្យមានការកើនឡើងនៃការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងបញ្ហានេះតាមប្រព័ន្ធផ្សព្វផ្សាយនានា ដោយមានយ៉ាងហោចណាស់២០អត្ថបទព័ត៌មានបានយោងតាមទិន្នន័យរបស់ខេមបូចា។

## ការអភិវឌ្ឍសមត្ថភាព

- វគ្គបណ្តុះបណ្តាលសរុបចំនួន ១៧ ត្រូវបានរៀបចំឡើង ដើម្បីបង្កើនជំនាញរាយការណ៍ព័ត៌មាន និងការការពារសុវត្ថិភាពសម្រាប់អ្នកសារព័ត៌មាន ព្រមទាំងផ្ដល់ឱកាសឱ្យយុវជនកម្ពុជាចំនួន៩នាក់ ហាត់ការដើម្បីអនុវត្តន៍ជំនាញ។
- អ្នកចូលរួមសរុបចំនួន ២១៦ នាក់ ពីក្រុមគោលដៅ បានទទួលឱកាសបន្ថែមចំណេះដឹង និងជំនាញ។
- ជាមធ្យម ៨២% នៃអ្នកចូលរួមវគ្គបណ្តុះបណ្តាល បានរាយការណ៍ថាចំណេះដឹង និងជំនាញរបស់ពួកគេមានការកើនឡើង បន្ទាប់ពីទទួលបានការបណ្តុះបណ្តាល។
- អ្នកហាត់ការព័ត៌មានទាំងអស់(១០០%) បានបង្ហាញការពេញចិត្តខ្ពស់ចំពោះបទពិសោធន៍ការងារនៅបន្ទប់ព័ត៌មានខេមបូចា ហើយជំនាញរាយការណ៍ព័ត៌មាន ក៏ដូចជាការយល់ដឹងអំពីបញ្ហាសង្គម និងជំនាញទន់ដូចជា ការទំនាក់ទំនង ការធ្វើការជាក្រុម និងប្រកបដោយភាពជន់មានការកើនឡើង ផងដែរ។

### ការអភិវឌ្ឍ និងការគ្រប់គ្រងអង្គភាព

- យុទ្ធសាស្ត្រ/ផែនការអាជីវកម្មសម្រាប់និរន្តរភាពរបស់ខេមបូចា ត្រូវបានរៀបចំតាមវិធីសាស្ត្រចូលរួម ដែលរួមបញ្ចូលទាំងមតិពីអ្នកអានតាមរយៈការវាយតម្លៃតម្រូវការអ្នកអាន និងមតិពីភាគីពាក់ព័ន្ធផ្សេងៗតាមរយៈការពិភាក្សាក្រុម (FGDs) និងសិក្ខាសាលាពិភាក្សា។
- ប្រព័ន្ធតាមដាន វាយតម្លៃ ទំនួលខុសត្រូវ និងរៀនសូត្រ (MEAL) ត្រូវបានបង្កើតឡើងដោយអ្នកប្រឹក្សាយោបល់នៅពាក់កណ្តាលឆ្នាំ ២០២៤ ហើយត្រូវបានគេរំពឹងថានឹងដំណើរការពេញលេញនៅឆ្នាំ ២០២៥ នៅពេលដែលអ្នកជំនាញផ្នែកនេះត្រូវបានជ្រើសរើស។
- គោលនយោបាយធនធានមនុស្ស ត្រូវបានពិនិត្យឡើងវិញ ដើម្បីធានាថាអនុលោមតាមច្បាប់ការងារជាតិពេញលេញ។
- វគ្គបណ្តុះបណ្តាលទាំងក្នុង និងក្រៅស្ថាប័ន ត្រូវបានរៀបចំធ្វើឡើង ជាច្រើនដង។ បុគ្គលិកសរុបចំនួន ២៧ នាក់ រួមទាំងអ្នក បានទទួលការបណ្តុះបណ្តាលលើប្រធានបទផ្សេងៗទាក់ទងនឹងបញ្ហាអង្គភាព ដូចជា សិទ្ធិអ្នកសារព័ត៌មាន សិទ្ធិការងារ ការវាយតម្លៃហានិភ័យ សុវត្ថិភាពរាងកាយនិងឌីជីថល ទាសភាពសម័យទំនើប សមភាពយេនឌ័រ សុវត្ថិភាពយេនឌ័រ ការបៀតបៀនផ្លូវភេទ ការការពារកុមារ ប្រព័ន្ធ MEAL ក៏ដូចជានីតិវិធីហិរញ្ញវត្ថុនិងលទ្ធកម្ម។

# អន្តរាគមន៍របស់ខេមបូចា

ក្នុងរយៈពេលនៃផែនការយុទ្ធសាស្ត្រ ឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨ យើងចង់ឃើញថា «អ្នកទស្សនាអាចបង្កើនការសម្រេចចិត្តដោយមានព័ត៌មានពេញលេញនៅក្នុងដៃ តាមរយៈការប្រើប្រាស់ព័ត៌មាន ដែលអាចទុកចិត្តបាន ដែលទទួលបានពី ឬ តាមរយៈខេមបូចា។ ខេមបូចា នឹងដោះស្រាយបញ្ហាចំនួន ៣ ដែលទាក់ទងគ្នា និងបំពេញគ្នាទៅវិញទៅមក។ ការផ្លាស់ប្តូរជាវិជ្ជមាន ដែលរំពឹងថាយើងនឹងសម្រេចបាន រួមមាន៖

១. បង្កើនការគាំទ្រ និងការការពារអ្នកសារព័ត៌មាន ដែលប្រឈមនឹងហានិភ័យ និង/ឬ ត្រូវបានបៀតបៀន។

២. ធ្វើឱ្យប្រសើរឡើងនូវបរិយាកាសនិងបទប្បញ្ញត្តិគាំទ្រប្រព័ន្ធផ្សព្វផ្សាយដែលអំណោយផលដល់ការអនុវត្តចំពោះវិស័យសារព័ត៌មាន។

៣. បង្កើនភាពអាចរកបាន និងលទ្ធភាពទទួលបានព័ត៌មានដែលអាចទុកចិត្តបាន សម្រាប់អ្នកទស្សនា។

# ការរកឃើញសំខាន់។

## វត្ថុបំណងទី១៖ បង្កើនការគាំទ្រ និងការការពារអ្នកសារព័ត៌មានដែលប្រឈមនឹងហានិភ័យ និង/ឬ ការបៀតបៀន

ដោយអនុលោមតាមផែនការសកម្មភាពរបស់អង្គការសហប្រជាជាតិស្តីពី សុវត្ថិភាពអ្នកសារព័ត៌មាននិងបញ្ហានិទ្ទណ្ឌភាព និងអនុសាសន៍របស់យន្តការពិនិត្យជាសកលតាមកាលកំណត់(UPR) ស្តីពីប្រព័ន្ធផ្សព្វផ្សាយ សកម្មភាពរបស់យើងក្នុងឆ្នាំ២០២៤ បានសង្កត់ធ្ងន់លើអន្តរាគមន៍ដ៏សំខាន់និងទាក់ទងគ្នាចំនួនបី ដោយផ្អែកលើវិធីសាស្ត្រនៃការផ្តល់សិទ្ធិអំណាចផ្អែកលើសិទ្ធិ។ អន្តរាគមន៍ទាំងនេះរួមមាន៖

១. បំពាក់ដល់អ្នកសារព័ត៌មាន នូវចំណេះដឹង ឧបករណ៍ និងជំនាញ ដើម្បីឱ្យពួកគេអាចឆ្លើយតបទៅនឹងហានិភ័យ ឬការគំរាមកំហែង។

២. ផ្តល់ជំនួយផ្នែកច្បាប់ ផ្លូវចិត្ត ជីវភាពរស់នៅ និង/ឬ ជំនួយសង្គ្រោះបន្ទាន់ ដល់អ្នកសារព័ត៌មាន និង/ឬ សមាជិកគ្រួសារ។

៣. ពង្រឹងសមត្ថភាពអ្នកសារព័ត៌មាន ឱ្យមានជំនាញក្នុងការសរសេរព័ត៌មាន និងក្រមសីលធម៌សារព័ត៌មាន ដូច្នេះពួកគេអាចផលិត និងផ្សព្វផ្សាយព័ត៌មានដែលអាចទុកចិត្តបាន ដើម្បីឱ្យអ្នកទស្សនាជាច្រើនអាចទទួលបាន។




*រូបភាពទី ១. អ្នកគ្រប់គ្រងផ្នែក ICT ( បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ) របស់ខេមបូចាបានធ្វើការបណ្តុះបណ្តាលបន្តដល់ក្រុមគោលដៅជុំវិញប្រធានបទសុវត្ថិភាពឌីជីថល និងការវាយតម្លៃហានិភ័យ។*

### ១. បំពាក់ដល់អ្នកសារព័ត៌មាន នូវចំណេះដឹង ឧបករណ៍ និងជំនាញ ដើម្បីឱ្យពួកគេអាចឆ្លើយតបទៅនឹងហានិភ័យ ឬការគំរាមកំហែង

សរុបមក វគ្គបណ្តុះបណ្តាលផ្ទាល់ចំនួន ៥ និងតាមអនឡាញចំនួន ៥ ត្រូវបានធ្វើឡើងសម្រាប់អ្នកសារព័ត៌មានក្នុងស្រុក។ វគ្គបណ្តុះបណ្តាលទាំង ៥ គ្របដណ្តប់លើប្រធានបទផ្សេងៗ រួមមានសុវត្ថិភាពឌីជីថល ការវាយតម្លៃហានិភ័យ ការរាយការណ៍ដែលគិតគូរពីយេនឌ័រ និងសុវត្ថិភាពយេនឌ័រ។ ចំនួននេះមិនរាប់បញ្ចូលវគ្គបណ្តុះបណ្តាល TOT (ការបណ្តុះបណ្តាលគ្រូឧទ្ទេស) រយៈពេល ៥ ថ្ងៃ ស្តីពីសមភាពយេនឌ័រ សមធម៌ ភាពជាអ្នកដឹកនាំ និងសុវត្ថិភាព ដែលត្រូវបានធ្វើឡើងដោយជោគជ័យនៅថ្ងៃទី ២៦-៣១ ខែមីនា ឆ្នាំ ២០២៤ នៅខេត្តសៀមរាប សម្រាប់អ្នកចូលរួមចំនួន ១៥ នាក់ ក្នុងនោះមានស្ត្រីចំនួន ១១ នាក់ ដែលពួកគេទាំងនោះជាបុគ្គលិកខេមបូចា សមាជិកក្រុមប្រឹក្សាភិបាល/សមាជិកស្នូលបណ្តាញអ្នកសារព័ត៌មានស្ត្រីកម្ពុជា(CFJ)តំណាងអ្នកសារព័ត៌មានតាមតំបន់នាបណ្តាខេត្ត អ្នកតស៊ូមតិសិទ្ធិប្រព័ន្ធផ្សព្វផ្សាយ និងអ្នកអប់រំសារព័ត៌មាន។ បន្ទាប់ពី ToT អ្នកចូលរួមដែលបានទទួលការបណ្តុះបណ្តាល បានផ្ទេរចំណេះដឹងរបស់ពួកគេ ទៅសមាជិកបណ្តាញរៀងៗខ្លួន តាមរយៈវគ្គបណ្តុះបណ្តាលដាច់ដោយឡែកចំនួនពីរ ដោយមានការគាំទ្រពីក្រុមការងារខេមបូចា។ ToT មួយទៀត ត្រូវបានរៀបចំឡើងដោយដៃគូខេមបូចា ស្តីពីសុវត្ថិភាពឌីជីថល និងការគ្រប់គ្រងហានិភ័យ ដែលបុគ្គលិកខេមបូចាចំនួន ៣ នាក់បានចូលរួម ហើយបន្ទាប់មកបានបន្តវគ្គការបណ្តុះបណ្តាលចំនួនពីរទៀត ទៅកាន់ក្រុមគោលដៅ។

**២. ផ្តល់ជំនួយផ្នែកច្បាប់ ផ្លូវចិត្ត ជីវភាពរស់នៅ និង/ឬ ជំនួយសង្គ្រោះបន្ទាន់ ដល់អ្នកសារព័ត៌មាន និង/ឬ សមាជិកគ្រួសារ**

តាមរយៈការសម្របសម្រួលនៃកម្មវិធីស្រាវជ្រាវ និងតស៊ូមតិរបស់ ខេមបូចា ជាមួយដៃគូក្នុងស្រុក អ្នកសារព័ត៌មានដែលត្រូវបានបៀតបៀនចំនួនពីររូប បានទទួលការគាំទ្រទាំងការគាំទ្រផ្នែកច្បាប់ និងជំនួយសង្គម។ ជាក់ស្តែងករណីអ្នកសារព័ត៌មានម្នាក់នៅខេត្តកំពង់ធំ ដែលបានជាប់ពន្ធនាគារ ទទួលបានជំនួយសង្គមពីដៃគូខេមបូចា ដែលជាអង្គការសមាជិកនៃក្រុមការងារសុវត្ថិភាពអ្នកសារព័ត៌មានដែលខេមបូចាបានផ្តួចផ្តើមនិងសម្របសម្រួល ដើម្បីលើកកម្ពស់ការឆ្លើយតបភ្លាមៗចំពោះតម្រូវការរបស់អ្នកសារព័ត៌មានដែលមានហានិភ័យ។ តាមរយៈការសម្របសម្រួលរបស់ខេមបូចាជាមួយក្រុមការងារ និងការិយាល័យអង្គការយូណេស្កូ នៅរាជធានីភ្នំពេញ អ្នកសារព័ត៌មានក៏លេចធ្លោ លោក មិុច ដារ៉ា ដែលបានជាប់ពន្ធនាគារដោយសារតែការបង្ហោះសាររិះគន់នៅលើហ្វេសប៊ុក របស់លោក ទទួលបានការការពារផ្នែកច្បាប់ពីមេធាវីក្នុងស្រុកដែលគួរឱ្យទុកចិត្ត និងជំនួយផ្សេងទៀត ដូចជាការតស៊ូមតិ និងជំនួយមនុស្សធម៌ជាដើម។

ដោយសហការជាមួយអង្គការក្នុងស្រុកនិងអន្តរជាតិផ្សេងៗ យើងបានចេញសេចក្តីថ្លែងការណ៍រួមមួយ ដែលគាំទ្រដោយអង្គការសង្គមស៊ីវិល និងអង្គការសារព័ត៌មានក្នុងស្រុក តំបន់ និងអន្តរជាតិចំនួន ៤៩។ ខេមបូចា បាននាំយកករណីនេះទៅក្រុមការងារសុវត្ថិភាពអ្នកសារព័ត៌មាន ដើម្បីបន្តធ្វើបច្ចុប្បន្នភាពសមាជិកអំពីការវិវត្តថ្មីៗនៅក្នុងករណីនេះ និងសម្របសម្រួលការផ្តល់ការគាំទ្រដល់លោក និងក្រុមគ្រួសាររបស់លោក។ ដារ៉ា ត្រូវបាន ដោះលែងឱ្យនៅក្រៅឃុំនៅថ្ងៃទី ២៤ ខែតុលា។



*រូបភាពទី ២. អ្នកសារព័ត៌មាន លោក មិុច ដារ៉ា ត្រូវបានដោះលែងឱ្យនៅក្រៅឃុំពីពន្ធនាគារខេត្តកណ្តាល នៅថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០២៤ បន្ទាប់ពីលោកបានសុំទោសប្រធានព្រឹទ្ធសភា លោក ហ៊ុន សែន និងនាយករដ្ឋមន្ត្រី លោក ហ៊ុន ម៉ាណែត។ ( ខេមបូចា/ព្រីង សំរាំង)*

## ៣. ពង្រឹងសមត្ថភាពអ្នកសារព័ត៌មានឱ្យមានជំនាញ និងក្រមសីលធម៌

វគ្គបណ្ដុះបណ្ដាលសរុបចំនួន ១០ ត្រូវបានធ្វើឡើងសម្រាប់ក្រុមគោលដៅដែលបានកំណត់។ វគ្គបណ្ដុះបណ្ដាលទាំងនេះរួមមានទាំងវគ្គបណ្ដុះបណ្ដាលចំនួន ៤ ដែលត្រូវបានរៀបចំឡើងសម្រាប់ក្រុមគោលដៅរបស់អង្គការដៃគូ ដោយផ្ដោតលើជំនាញមូលដ្ឋានសរសេរព័ត៌មាន និងការរាយការណ៍តាមទូរស័ព្ទដៃ។ គោលដៅគឺដើម្បីផ្ដល់សិទ្ធិអំណាចដល់ពួកគេដែលជាអ្នកសារព័ត៌មានពលរដ្ឋ ដើម្បីប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយឱ្យមានប្រសិទ្ធភាពជាងមុន នៅពេលរាយការណ៍បញ្ហានៅក្នុងសហគមន៍ ឬវិស័យរបស់ពួកគេ។

បន្ថែមពីលើការបណ្ដុះបណ្ដាល អ្នកហាត់ចំនួន៩នាក់ (ស្ត្រី ២នាក់) បានទទួលឱកាសហាត់ការចាប់ពី ៣ ទៅ ៦ ខែ ដើម្បីអភិវឌ្ឍជំនាញសារព័ត៌មានរបស់ពួកគេ។ ក្នុងចំណោមអ្នកហាត់ការទាំងនោះ អ្នកហាត់ការជាស្ត្រីចំនួន ២ នាក់ និងបុរសម្នាក់ បានបន្តការចូលរួមរបស់ពួកគេនៅក្នុងវិស័យសារព័ត៌មាន ដោយចូលរួមធ្វើជាអ្នករាយការណ៍ឯករាជ្យ និងសុំបន្តពេលហាត់របស់លោកនៅស្ថាប័នសារព័ត៌មានមួយផ្សេងទៀត។

មនុស្សចំនួនសរុប ២១៦ នាក់ មកពីក្រុមគោលដៅបានទទួលឱកាសដើម្បីបង្កើនជំនាញ និងចំណេះដឹងរបស់ពួកគេ តាមរយៈវគ្គបណ្ដុះបណ្ដាលចំនួន ១៧ ដែលផ្ដោតលើជំនាញរាយការណ៍ព័ត៌មាន ការយល់ដឹងអំពីក្រមសីលធម៌ ច្បាប់ទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយ ការការពារសុវត្ថិភាព និងសន្តិសុខ និងផ្ដល់ឱកាសហាត់ការចំនួន ៩ កន្លែង ដល់យុវជនកម្ពុជា ដើម្បីពង្រឹងជំនាញរាយការណ៍របស់ពួកគេ។ អ្នកទទួលផលរួមមាន យុវជនចំនួន ១៥៤នាក់ ដែលមានអាយុចន្លោះពី ១៨ ទៅ ៣៥ ឆ្នាំ (៧១%) ស្ត្រី ៨៨ នាក់ (៤១%) និងអ្នកសារព័ត៌មាន/អ្នកសារព័ត៌មានពលរដ្ឋ ដែលមានមូលដ្ឋាននៅតាមបណ្ដាខេត្តចំនួន ១២៨ នាក់ (៥៩%)។ ចំនួននេះមិនរាប់បញ្ចូលវគ្គចែករំលែក និងកសាងបណ្ដាញតាមអនឡាញចំនួន ៥ ដែលរៀបចំឡើងសម្រាប់អ្នកព័ត៌មានក្នុងតំបនតាមបណ្ដាខេត្ត និងវគ្គបណ្ដុះបណ្ដាលសុខុមាលភាព និងភាពធន់ចំនួន ១ លើកសម្រាប់សមាជិកបណ្ដាញអ្នកសារព័ត៌មានស្ត្រីកម្ពុជា (CFJ) នោះទេ។

ជាមធ្យម ៨២% នៃអ្នកចូលរួមដែលបានទទួលការបណ្ដុះបណ្ដាលបានរាយការណ៍ចំណេះដឹង និងជំនាញរបស់ពួកគេកើនឡើង បន្ទាប់ពីវគ្គបណ្ដុះបណ្ដាល។ អ្នកហាត់ការជាអ្នករាយការណ៍ព័ត៌មានទាំង ៩ នាក់សុទ្ធតែបាន បង្ហាញកម្រិតខ្ពស់នៃការពេញចិត្តចំពោះបទពិសោធន៍ហាត់ការរបស់ពួកគេនៅបន្ទប់ព័ត៌មានខេមបូចា ដោយបានរាយការណ៍ពីការកើនឡើងនូវជំនាញរាយការណ៍ព័ត៌មាន ចំណេះដឹងអំពីបញ្ហាសង្គម និងការកែលម្អជំនាញទន់ ដូចជាការប្រាស្រ័យទាក់ទង ការងារជាក្រុម និងភាពធន់ជាដើម។

«ការធ្វើជាអ្នករាយការណ៍ព័ត៌មានវីដេអូ គឺជាការងារដ៏លំបាកមួយ ប៉ុន្តែបន្ទាប់ពីធ្វើការនៅខេមបូចា ខ្ញុំទទួលបានភាពក្លាហាន និងទំនុកចិត្ត។ ខេមបូចា ក៏បានបង្រៀនខ្ញុំនូវមេរៀនដ៏មានតម្លៃជាច្រើនផងដែរ ហើយសម្រាប់ការធ្វើដំណើរកាងារបន្ទាប់របស់ខ្ញុំ ខ្ញុំសង្ឃឹមថា នឹងអាចធ្វើការជាអ្នករាយការណ៍ព័ត៌មានវីដេអូនៅអង្គការឯករាជ្យមួយដូចជាខេមបូចា ដែរ»។

**ហ៊ែល កំសាន អ្នកហាត់ការជាអ្នករាយការណ៍ព័ត៌មានវីដេអូ**

«ក្នុងអំឡុងពេលហាត់ការរយៈពេលប្រាំមួយខែរបស់ខ្ញុំ ក្នុងនាមជាអ្នកហាត់ការជាអ្នករាយការណ៍ព័ត៌មានវីដេអូនៅខេមបូចា ខ្ញុំបានរាយការណ៍រឿងរ៉ាវផ្សេងៗ ដូចជាបញ្ហាសិទ្ធិមនុស្ស នយោបាយ បរិស្ថាន គណនេយ្យភាពសង្គម និងព្រឹត្តិការណ៍ផ្សេងៗ។ ការរៀនធ្វើជាអ្នករាយការណ៍ព័ត៌មានវីដេអូក្នុងអំឡុងពេលការហាត់ការ គឺជាវិធីដ៏ល្អមួយដើម្បីទទួលបានបទពិសោធន៍ជាក់ស្តែង។ ខ្ញុំបានរៀនទាំងជំនាញទន់ និងជំនាញរឹង នៅក្នុងវិស័យនេះ»។

**ឡេង លួត អ្នកហាត់ការជាអ្នករាយការណ៍ព័ត៌មានវីដេអូ**

«ខ្ញុំបានរៀនពីរបៀបលើកឡើងនូវគំនិតរឿង និងកំណត់ថាតើរឿងណាខ្លះដែលមានតម្លៃគួរសរសេរ និងតាមដាន។ ខ្ញុំទទួលបានបទពិសោធន៍ក្នុងការធ្វើការជាក្រុម ជាពិសេសជាមួយមិត្តរួមការងារជាអ្នកហាត់ការដូចគ្នា និងអ្នករាយការណ៍ព័ត៌មានចាស់ៗដែលមានបទពិសោធន៍។ ខ្ញុំបានអភិវឌ្ឍជំនាញក្នុងការសួរសំណួរស៊ីជម្រៅ និងសំណួរប្រដេញក្នុងអំឡុងពេលសម្ភាសន៍។ ខ្ញុំបានសរសេររឿងពាក់ព័ន្ធនឹងប្រធានបទជាច្រើន ដែលបានជួយខ្ញុំឱ្យរកឃើញចំណាប់អារម្មណ៍របស់ខ្ញុំ ជាពិសេសលើប្រធានបទដូចជាការអប់រំ និងកិច្ចការសង្គម»។

**តាំង ប៉ហ្គិច អ្នកហាត់ការជាអ្នករាយការណ៍ព័ត៌មាន**

«ក្នុងអំឡុងពេលការហាត់ការរយៈពេលប្រាំមួយខែរបស់ខ្ញុំ ខ្ញុំទទួលបានបទពិសោធន៍ដ៏ល្អ តាមរយៈការរាយការណ៍របស់ខ្ញុំ ព្រោះថាមានព្រឹត្តិការណ៍ជាច្រើនបានកើតឡើងក្នុងអំឡុងពេលនោះ។ ព្រឹត្តិការណ៍ទាំងនោះរួមមាន ការចាប់ខ្លួនសកម្មជនអង្គការមាតាធម្មជាតិ ឧក្រិដ្ឋកម្ម ការបោកប្រាស់ ការធ្វើមាតុភូមិនិវត្តន៍ពលករចំណាកស្រុកពីប្រទេសអារ៉ាប៊ីសាអូឌីត គម្រោងព្រែកជីកហ្វូណនតេជោ កិច្ចប្រជុំកំពូល CLV-DTA ទស្សនកិច្ចរបស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ និងការតវ៉ាផ្សេងៗ។ ខ្ញុំបានរៀនសូត្រជាច្រើនពីព្រឹត្តិការណ៍បច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា ជាពិសេសអំពីបញ្ហាបរិស្ថាន តាមរយៈការងាររបស់ខ្ញុំហើយទទួលបានការយល់ដឹងកាន់តែស៊ីជម្រៅអំពីបរិបទជុំវិញរឿងរ៉ាវដែលខ្ញុំបានសរសេរផ្សាយ»។

**លី រ៉ូស្លាន អ្នកហាត់ការជាអ្នករាយការណ៍ព័ត៌មាន**

# វត្ថុបំណងទី២៖ តស៊ូមតិដើម្បីឱ្យមានបរិយាកាសនិងបទប្បញ្ញត្តិគាំទ្រប្រព័ន្ធផ្សព្វផ្សាយដែលអំណោយផលដល់វិស័យសារព័ត៌មាន

សកម្មភាពកម្មវិធីសំខាន់ៗចំនួនបី ដែលត្រូវបានអនុវត្តនៅក្នុងឆ្នាំ ២០២៤ រួមមាន៖ (១) ការតាមដាន និងកត់ត្រាករណីហិង្សាលើអ្នកសារព័ត៌មាន និងបរិយាកាសច្បាប់នៅក្នុងប្រទេស (២) ការរៀបចំ និងចូលរួមក្នុងសកម្មភាពតស៊ូមតិនៅគ្រប់កម្រិត និង (៣) ការបង្កើនការយល់ដឹងជាសាធារណៈអំពីសេរីភាពនៃការបញ្ចេញមតិ (FOE) វិជ្ជាជីវៈ និងក្រមសីលធម៌សារព័ត៌មាន។

របាយការណ៍ប្រចាំត្រីមាសចំនួន ៤ ស្តីពីសុវត្ថិភាពអ្នកសារព័ត៌មាន និងរបាយការណ៍តាមដានប្រចាំឆ្នាំចំនួន ១ ដែលផ្តោតលើស្ថានភាពសុវត្ថិភាពរបស់អ្នកសារព័ត៌មានក្នុងឆ្នាំ ២០២៣ ត្រូវបានបោះពុម្ព និងផ្សព្វផ្សាយក្នុងចំណោមអ្នកពាក់ព័ន្ធសំខាន់ៗ និងសាធារណជន តាមរយៈគេហទំព័រ គណនីបណ្តាញសង្គម ព្រឹត្តិការណ៍ និងវេទិកាផ្សេងទៀតសម្រាប់ការបញ្ចុះបញ្ចូលនិងការចូលរួមជាមួយដៃគូអភិវឌ្ឍន៍ដោយផ្អែកលើទិន្នន័យដែលប្រមូលបានតាមរយៈការតាមដាន។ ទោះបីជាមិនមានករណី អំពើហិង្សាផ្អែកលើយេនឌ័រ ត្រូវបានរាយការណ៍កាលពីឆ្នាំមុនក៏ដោយ បទពិសោធន៍ និងកង្វល់អំពីសុវត្ថិភាពរបស់អ្នកសារព័ត៌មានស្ត្រី ត្រូវបានគូសបញ្ជាក់ជាសាធារណៈតាមរយៈអត្ថបទស៊ីជម្រៅ វីដេអូ និងព្រឹត្តិការណ៍នានា ដែលមានគោលបំណងបង្កើនការយល់ដឹងក្នុងចំណោមអ្នកពាក់ព័ន្ធ។អត្ថបទទាំងនោះអាចចូលមើលបាននៅលើគេហទំព័រ www.camboja.net/advocacy។ កិច្ចខិតខំប្រឹងប្រែងផ្នែកទំនាក់ទំនងរបស់យើង បាននាំឱ្យមានការកើនឡើងនូវការផ្សព្វផ្សាយព័ត៌មានអំពីបញ្ហាទាំងនេះ ដោយមានអត្ថបទព័ត៌មានយ៉ាងហោចណាស់ ២០ បានយោងលើទិន្នន័យរបស់ខេមបូចា។

**របាយការណ៍ស្តីពីស្ថានភាពសារព័ត៌មាននៅកម្ពុជាឆ្នាំ២០២៣៖**
https://www.camboja.net/advocacy/reports/annual-report/cambodian-journalism-situation-report-2023/

**របាយការណ៍ប្រចាំត្រីមាស (ខែតុលា ដល់ខែធ្នូ ឆ្នាំ២០២៣)៖**
https://www.camboja.net/advocacy/reports/quarterly-report/quarterly-monitoring-report-on-journalism-situation-in-cambodia-october-december-2023/

**របាយការណ៍ប្រចាំត្រីមាស (ខែមករា ដល់ខែមីនា ឆ្នាំ២០២៤)៖**
https://www.camboja.net/advocacy/reports/quarterly-report/quarterly-monitoring-report-on-journalism-situation-in-cambodia-january-march-2024/

**របាយការណ៍ប្រចាំត្រីមាស (ខែមេសា ដល់ខែមិថុនា ឆ្នាំ២០២៤)៖**
https://www.camboja.net/advocacy/reports/quarterly-report/quarterly-monitoring-report-on-journalism-situation-in-cambodia-april-june-2024/

**របាយការណ៍ប្រចាំត្រីមាស (ខែកក្កដា ដល់ខែកញ្ញា ឆ្នាំ២០២៤)៖**
https://www.camboja.net/advocacy/reports/quarterly-report/quarterly-monitoring-report-on-journalism-situation-in-cambodia-july-september-2024/

របាយការណ៍ប្រចាំត្រីមាស (ខែតុលា ដល់ខែធ្នូ ឆ្នាំ២០២៤) នឹងត្រូវបោះពុម្ពនៅចន្លោះពាក់កណ្ដាលខែមករា និងដើមខែកុម្ភៈ ឆ្នាំ២០២៥។ របាយការណ៍ប្រចាំឆ្នាំគ្របដណ្ដប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២៤ ដែលនឹងត្រូវបោះពុម្ពនៅខែមីនា ឆ្នាំ២០២៥ ដើម្បីផ្ដល់នូវទិដ្ឋភាពជាទូទៅនៃនិន្នាការសំខាន់ៗពាក់ព័ន្ធនឹងការគំរាមកំហែងសុវត្ថិភាពដែលយើងបានចងក្រងជាឯកសារកាលពីឆ្នាំមុន។

**ក្របខណ្ឌត្រួតពិនិត្យសុវត្ថិភាពអ្នកសារព័ត៌មានគ្រប់ជ្រុងជ្រោយមួយត្រូវបានបង្កើត និងដាក់ឱ្យដំណើរការ**

ដើម្បីបង្កើនភាពជឿជាក់នៃទិន្នន័យរបស់យើង ក្របខ័ណ្ឌត្រួតពិនិត្យគ្រប់ជ្រុងជ្រោយមួយត្រូវបានបង្កើតឡើងដោយសហការជាមួយអ្នកជំនាញប្រព័ន្ធផ្សព្វផ្សាយសំខាន់ៗ និងការិយាល័យអង្គការយូណេស្កូ ដោយធានាបាននូវការប្រមូលទិន្នន័យដែលអាចទុកចិត្តបាន និងផ្អែកលើភស្តុតាង ហើយរួមចំណែកដល់ចំណុចដូចខាងក្រោម៖

- បានធ្វើឱ្យប្រសើរឡើងនូវសុវត្ថិភាពអ្នកសារព័ត៌ តាមរយៈការកត់ត្រា និងផ្ទៀងផ្ទាត់ឧប្បត្តិហេតុជាច្រើនដែលនាំទៅដល់ការធ្វើអន្តរាគមន៍ជាយុទ្ធសាស្ត្រ ដែលដោះស្រាយកង្វល់ផ្នែកច្បាប់ ឌីជីថល និងសុវត្ថិភាពផ្លូវចិត្ត។ ក្របខ័ណ្ឌនេះក៏បានពង្រឹងសមត្ថភាពរបស់ខេមបូចា ក្នុងការត្រួតពិនិត្យ និងបង្ហាញលក្ខខណ្ឌជុំវិញសុវត្ថិភាពរបស់អ្នកសារព័ត៌មានផងដែរ។ វាបានបង្កើនចំណេះដឹងរបស់បុគ្គលិកពីដៃគូសំខាន់ៗនៃសូចនាករសុវត្ថិភាពរបស់អង្គការយូណេស្កូ និងទំនាក់ទំនងរវាងការវាយប្រហារលើអ្នកសារព័ត៌មាន និងការរំលោភសិទ្ធិមនុស្ស។
- បានបង្កើនការយល់ដឹង និងកិច្ចខិតខំប្រឹងប្រែងតស៊ូមតិដោយបានភ្ជាប់អ្នកសារព័ត៌មានដែលមានហានិភ័យ ជាមួយនឹងបណ្ដាញជំនួយ និងបានគូសបញ្ជាក់ពីបញ្ហាសេរីភាពសារព័ត៌មាននៅក្នុងប្រទេសកម្ពុជា។

ក្នុងអំឡុងពេលនៃការអភិវឌ្ឍក្របខណ្ឌត្រួតពិនិត្យសុវត្ថិភាពអ្នកសារព័ត៌មាន អ្នកសារព័ត៌មានស្ត្រី និងអ្នកជំនាញផ្នែកយេនឌ័របានចូលរួម ដើម្បីធានាបាននូវវិធីសាស្ត្រដែលគិតគូរពីយេនឌ័រ និងបង្កើតសូចនាករជាក់លាក់សម្រាប់ការកត់ត្រាករណីអំពើហិង្សាផ្អែកលើយេនឌ័រ (GBV)។ ព្រឹត្តិការណ៍បែបកូនកាត់មួយត្រូវបានធ្វើឡើងនៅថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០២៤ ដើម្បីដាក់ឱ្យដំណើរការក្របខ័ណ្ឌត្រួតពិនិត្យសុវត្ថិភាពអ្នកសារព័ត៌មានដែលបានបញ្ចប់ជាផ្លូវការ ដល់អ្នកពាក់ព័ន្ធដែលជាក្រុមគោលដៅ និងលើកទឹកចិត្តឱ្យប្រើប្រាស់ទិន្នន័យដែលមាន ដើម្បីជូនដំណឹងដល់ការធ្វើអន្តរាគមន៍នាពេលអនាគតលើសុវត្ថិភាពសារព័ត៌មាននៅក្នុងប្រទេសកម្ពុជា។ ព្រឹត្តិការណ៍នេះមានអ្នកចូលរួមចំនួន ៦៥ នាក់ដោយផ្ទាល់ (ស្ត្រី ២០ នាក់) និងអ្នកចូលរួមចំនួន ២៣ នាក់ តាមរយៈសិក្ខាសាលាតាម Zoom (ធៀបនឹងអ្នកចូលរួមដែលកំណត់យកតែចំនួន ៤០ នាក់)។ អ្នកចូលរួមរួមមាន អ្នកសារព័ត៌មានតំណាងមកពីស្ថានទូត អង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល មេធាវី និងវិទ្យាស្ថាន/ក្រសួងរបស់រដ្ឋាភិបាល។ បន្ទាប់ពីការដាក់ឱ្យដំណើរការ ស្ថាប័នសារព័ត៌មានក្នុងស្រុក មានវិទ្យុបារាំងអន្តរជាតិ (RFI) វិទ្យុវាយោ និងសារព័ត៌មានដំរី បានរាយការណ៍អំពីព្រឹត្តិការណ៍នេះ ដែលការចុះផ្សាយទាំងនោះបានបង្កើនការយល់ដឹងជាសាធារណៈជុំវិញក្របខណ្ឌត្រួតពិនិត្យនេះ។

## ការតស៊ូមតិសម្រាប់ការពិគ្រោះយោបល់ប្រកបដោយអត្ថន័យលើធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន

ការវិវត្តដ៏សំខាន់បំផុតមួយនៅក្នុងឧស្សាហកម្មសារព័ត៌មានរបស់ប្រទេសកម្ពុជានៅក្នុងឆ្នាំ ២០២៤ គឺការដាក់ឱ្យដំណើរការធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មានដោយក្រសួងព័ត៌មាននៅថ្ងៃទី ៦ ខែសីហា ដោយមានគោលបំណង «បង្កើតសណ្តាប់ធ្នាប់» នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ និងពង្រឹងក្រមសីលធម៌សារព័ត៌មាន។

ដោយផ្អែកលើធាតុចូលដែលប្រមូលបាន ខេមបូចាបានរៀបចំលិខិតរួមមួយ ហើយដាក់ស្នើទៅក្រសួងព័ត៌មាន ដោយស្នើសុំឱ្យក្រសួងផ្អាកការអនុវត្តធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាននេះ និងទាមទារឱ្យមានដំណើរការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ។ យើងក៏បានចូលរួមយ៉ាងជិតស្និទ្ធជាមួយទីភ្នាក់ងារអង្គការសហប្រជាជាតិ គឺ អង្គការយូណេស្កូ និង ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ដើម្បីកៀរគរការគាំទ្រផ្នែកតស៊ូមតិផងដែរ។ (សូមមើលឧបសម្ព័ន្ធសម្រាប់ព័ត៌មានលម្អិតស្តីពីអនុសាសន៍របស់អង្គការសង្គមស៊ីវិលទាក់ទងនឹងធម្មនុញ្ញនេះ - មានតែភាសាខ្មែរប៉ុណ្ណោះ)។


JOURNALISTS POLITICS SOCIAL ENVIRONMENT HUMAN RIGHTS BUSINESS OPINION

UN Calls for Suspension Of Cambodia's Journalism Charter, Ministry Says It Devalues Industry's Consensus

14 September 2024 7:45 AM | Seoung Nimol

Information Minister Neth Pheaktra speaks at a press conference to launch the Charter for Professional Journalism on August 6, 2024, a photo post on the Ministry of Information's Facebook.

LATEST NEWS

Cambodia Again Ranks Second to Last on Rule of Law Index; Officials Dismiss Findings
4 Nov 2024

Intl Forum Demands Action on Unpunished Crimes Against Cambodian Journalists; Formerly Jailed Journalist Weighs in
1 Nov 2024

Cambodia's Media Pushes for Independent Oversight
31 Oct 2024

Nearly 80% of 12th Graders Pass Final Exam, Up 10%
30 Oct 2024

King Sihamoni's 20th Coronation Celebration Ends with Call for National Unity
30 Oct 2024

MOST VIEWED

1 Armed Forces To Root Out Extremist

*រូបភាពទី ៣. រូបថតពីអេក្រង់នៃអត្ថបទព័ត៌មានខេមបូចា ស្តីពីការអំពាវនាវរបស់អង្គការសហប្រជាជាតិឱ្យផ្អាកធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន។*

**អនុសាសន៍ចំនួន ១៧ ចំណុច ដាក់ជូនរដ្ឋាភិបាល**

យើងបានបន្តអំពាវនាវដល់រដ្ឋាភិបាល និងអាជ្ញាធរពាក់ព័ន្ធឱ្យលើកកម្ពស់សេរីភាពសារព័ត៌មាន និងការគោរពកាតព្វកិច្ចវិជ្ជាជីវៈរបស់អ្នកសារព័ត៌មាន ដូចជាការរក្សាការសម្ងាត់ប្រភពព័ត៌មាន ក៏ដូចជាការបង្ហាញការប្តេជ្ញាចិត្តក្នុងការបញ្ចប់ការយាយីអ្នកសារព័ត៌មាន។ ជាពិសេស យើងជំរុញឱ្យអាជ្ញាធរ និងបុគ្គលឯកជនៈ

១. ចៀសវាងការចោទប្រកាន់បទព្រហ្មទណ្ឌលើអ្នកសារព័ត៌មាន និងអ្នកសារព័ត៌មានពលរដ្ឋ ពាក់ព័ន្ធនឹងការងារសារព័ត៌មាន អ្នកសារព័ត៌មានពលរដ្ឋ អ្នកការពារសិទ្ធិមនុស្ស និងអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម។

២. បញ្ចប់និទ្ទណ្ឌភាព តាមរយៈការស៊ើបអង្កេត កាត់ទោស និងដោះស្រាយករណីហិង្សាលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សឱ្យបានឆាប់រហ័ស។

៣. ផ្តល់ការគាំទ្រ ការបណ្តុះបណ្តាល និងធនធានដល់អង្គភាពដែលទទួលបន្ទុកស៊ើបអង្កេតបទឧក្រិដ្ឋប្រឆាំងនឹងអ្នកសារព័ត៌មាន រួមទាំងការស៊ើបអង្កេតបទឧក្រិដ្ឋបែបនេះ តាមរបៀបដែលគិតគូរពីយេនឌ័រ។

៤. ទម្លាក់ចោលការចោទប្រកាន់ដែលនៅសេសសល់ជាបន្ទាន់ និងពិនិត្យមើលការកាត់ទោសព្រហ្មទណ្ឌលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស និងស៊ើបអង្កេតករណីហិង្សាប្រឆាំងនឹងក្រុមទាំងនេះ។

៥. បង្កើត និងអនុវត្តកម្មវិធីបណ្តុះបណ្តាលសម្រាប់អាជ្ញាធរអនុវត្តច្បាប់ ស្តីពីការគោរពសិទ្ធិអ្នកសារព័ត៌មានក្នុងការរាយការណ៍ និងកត់ត្រានៅក្នុងពេលមានបាតុកម្មតវ៉ា និងព្រឹត្តិការណ៍សាធារណៈផ្សេងទៀត។

៦. ធ្វើច្បាប់ស្តីពីការផ្សព្វផ្សាយ ដែលបង្កើតអាជ្ញាធរផ្សព្វផ្សាយឯករាជ្យ និងច្បាប់ច្បាស់លាស់ និងអព្យាក្រឹតសម្រាប់ការបែងចែកអាជ្ញាបណ្ណផ្សាយ ស្របតាមស្តង់ដារអន្តរជាតិ។

៧. បង្កើតច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ដែលស្របតាមស្តង់ដារអន្តរជាតិក្នុងឆ្នាំ ២០២៥។

៨. ធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌ ដើម្បីឱ្យស្របតាមស្តង់ដារសេរីភាពនៃការបញ្ចេញមតិអន្តរជាតិ រួមទាំងការលុបចោល ឬធ្វើវិសោធនកម្មបទល្មើសញុះញង់ (មាត្រា ៤៩៤, ៤៩៥) និងលុបចោលបទល្មើសប្រមាថព្រះមហាក្សត្រ (មាត្រា ៤៣៧-ប៊ីស) ការបរិហារកេរ្តិ៍ជាសាធារណៈ (មាត្រា ៣០៥) និងការជេរប្រមាថជាសាធារណៈ (មាត្រា ៣០៧)។

៩. ធ្វើវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មាន ដើម្បីឱ្យស្របតាមស្តង់ដារអន្តរជាតិ បង្កើតច្បាប់ច្បាស់លាស់ជុំវិញការទទួលស្គាល់សារព័ត៌មាន និងការចុះឈ្មោះសារព័ត៌មាន ហើយអនុញ្ញាតិឲ្យធ្វើប្រតិបត្តិការដោយសេរីសម្រាប់ប្រព័ន្ធផ្សព្វផ្សាយអនឡាញ។

១០. លុបចោលប្រកាសរបស់ក្រសួងព័ត៌មាន ដែលអនុញ្ញាតឱ្យរដ្ឋាភិបាលដកហូតអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយដោយគ្មានដំណើរការនីតិវិធីយុត្តិធម៌ ដែលបំពានគោលការណ៍សេរីភាពសារព័ត៌មាន និងមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញកម្ពុជា។

១១. លុបចោលប្រកាសអន្តរក្រសួងលេខ១៧០ ដែលត្រូវបានប្រើដើម្បីដកហូតអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយដោយគ្មានសេចក្តីសម្រេចរបស់តុលាការ ក៏ដូចជាផ្តល់អំណាចដល់រដ្ឋាភិបាលក្នុងការបញ្ជាឱ្យ ISP បិទគេហទំព័រ និងអនុក្រឹត្យស្តីពីការចុះឈ្មោះឈ្មោះដែន(domain) ការចុះឈ្មោះស៊ីមកាតជាកាតព្វកិច្ច និងច្រកទ្វារអ៊ីនធឺណិតជាតិ។

១២. ដាក់កម្រិតច្បាស់លាស់លើអំណាចរបស់អាជ្ញាធរក្នុងការចូលរួមក្នុងការឃ្លាំមើល និងបិទគេហទំព័រអ៊ីនធឺណិតដោយគ្មានដីកាពីតុលាការ និងកែសម្រួលច្បាប់ទូរគមនាគមន៍ឱ្យស្របតាមស្តង់ដារអន្តរជាតិ។

១៣. ធ្វើការពិគ្រោះយោបល់ប្រកបដោយអត្ថន័យលើសេចក្តីព្រាងច្បាប់ដែលប៉ះពាល់ដល់សេរីភាពនៃការបញ្ចេញមតិ ដើម្បីអនុញ្ញាតឱ្យសង្គមស៊ីវិលផ្តល់ធាតុចូល និងធានាឱ្យស្របតាមកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធនយោបាយ ដែលក្នុងនោះរួមមានសេចក្តីព្រាងច្បាប់ដែលទាក់ទងនឹងឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត សន្តិសុខតាមអ៊ីនធឺណិត និងការការពារទិន្នន័យផ្ទាល់ខ្លួន។

១៤. បង្កើនការទទួលបានអ៊ីនធឺណិតសម្រាប់ប្រើប្រាស់ដល់ពលរដ្ឋរបស់ខ្លួន ដើម្បីធានាថាប្រជាជនកម្ពុជាទាំងអស់អាចទទួលបានព័ត៌មានតាមអ៊ីនធឺណិត។ ករណីនេះអាចត្រូវបានធ្វើដោយ៖

- ធានាបាននូវសមភាពក្នុងការទទួលបានសម្រាប់ក្រុមដែលរងភាពងាយរងគ្រោះ រួមមានស្ត្រី ជនពិការ និងជនជាតិភាគតិច។
- លើកទឹកចិត្តដល់វិស័យទូរគមនាគមន៍ ឱ្យផ្តល់ជម្រើសដែលមានតម្លៃទាបទាំងនៅតំបន់ប្រជុំជន និងជនបទ តាមរយៈការលើកលែងពន្ធ ការឧបត្ថម្ភធន ឬគម្រោងស្រដៀងគ្នា។
- ពង្រីកសេវាទូរស័ព្ទចល័តនៅតំបន់ជនបទ អមដោយឥណទាន ឬប្រាក់ឧបត្ថម្ភដល់ប្រជាពលរដ្ឋដែលមិនមានលទ្ធភាពប្រើប្រាស់អ៊ីនធឺណិត ឬឧបករណ៍ផ្ទាល់ខ្លួន។
- បង្កើតមជ្ឈមណ្ឌលអ៊ីនធឺណិតសហគមន៍ ដើម្បីជាកន្លែងឱ្យសមាជិកសហគមន៍អាចប្រើប្រាស់អ៊ីនធឺណិត និងកុំព្យូទ័រ ដោយឥតគិតថ្លៃ ឬក្នុងតម្លៃទាប។

១៥. បង្កើនការអប់រំផ្នែកអក្ខរកម្មឌីជីថល ទាំងនៅក្នុងគ្រឹះស្ថានអប់រំផ្លូវការ ដូចជាសាលារៀន និងសាកលវិទ្យាល័យ ក៏ដូចជានៅក្នុងគ្រឹះស្ថានអប់រំក្រៅផ្លូវការ។ គោលដៅគឺដើម្បីឱ្យប្រជាជនកម្ពុជាអាចបែងចែកប្រភពព័ត៌មានពិត និង ប្រភពព័ត៌មានមិនពិត ក៏ដូចជាអាចវាយតម្លៃព័ត៌មានដែលពួកគេទទួលបាន។

១៦. បង្កើតដំណើរការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយប្រព័ន្ធផ្សព្វផ្សាយ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីធានាថាវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មានស្របតាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ។

១៧. ស្នើដល់ក្រសួងព័ត៌មានឱ្យធានាថាអ្នកសារព័ត៌មានអាចទទួលបានបណ្ណសារព័ត៌មានទាន់ពេលវេលា និងដោយតម្លាភាព ហើយដោយគ្មានការរើសអើងណាមួយឡើយ។

**ការកសាងសម្ព័ន្ធភាព**

**ភាពជាដៃគូថ្នាក់មូលដ្ឋានក្រោមជាតិ**

តាមរយៈគម្រោងអង្គការយូណេស្កូ ដែលផ្តល់មូលនិធិដោយ SIDA ដែលគាំទ្រការបង្កើត និងពង្រឹងបណ្តាញអ្នកសារព័ត៌មានថ្នាក់មូលដ្ឋានក្រោមជាតិ ខេមបូចាបានបន្តសហការជាមួយអ្នកសារព័ត៌មាន ប្រចាំខេត្តដែលមានមូលដ្ឋាននៅតំបន់ភាគឦសាន និងពាយ័ព្យ។ សាខានីមួយៗត្រូវបានសម្របសម្រួលដោយអ្នកសម្របសម្រួលម្នាក់ ដែលជាសមាជិកអាជីពរបស់សមាគម។

**ភាពជាដៃគូថ្នាក់ជាតិ**

ក្រុមការងារសុវត្ថិភាពអ្នកសារព័ត៌មានដែលមានខេមបូចា និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកចំនួនពីរផ្សេងទៀត ដែលធ្វើការដើម្បីការពារប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងអ្នកការពារសិទ្ធិមនុស្ស បណ្តាញអ្នកសារព័ត៌មានស្ត្រីកម្ពុជា (CFJ) ក្លឹបសារព័ត៌មានបរទេសប្រចាំកម្ពុជា (OPCC) ក្រុមការងារសិទ្ធិឌីជីថលដែលដឹកនាំដោយអង្គការសង្គមស៊ីវិល និងក្រុមការងារសិទ្ធិទទួលបានព័ត៌មានដែលដឹកនាំដោយអង្គការសង្គមស៊ីវិល សម្របសម្រួលដោយវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ ត្រូវបានពង្រឹងជាមួយនឹងការតស៊ូមតិរួមគ្នា និងសមត្ថភាពឃ្លាំមើលកាន់តែខ្លាំងជាងមុន។

**ភាពជាដៃគូក្នុងតំបន់**

ក្នុងនាមជាសមាជិកនៃសម្ព័ន្ធភាពក្នុងតំបន់ ដើម្បីតាមដានការវាយប្រហារលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ខេមបូចា បានចែករំលែកទិន្នន័យត្រួតពិនិត្យសុវត្ថិភាពអ្នកសារព័ត៌មានថ្នាក់ជាតិ ជាមួយវេទិកាក្នុងតំបន់ (pfmsea.org) និងបានធ្វើសកម្មភាពតស៊ូមតិរួមគ្នា ដើម្បីទាមទារឱ្យមានការទទួលខុសត្រូវរបស់អ្នកដែលពាក់ព័ន្ធនឹងករណីវាយប្រហារជាច្រើនប្រឆាំងនឹងអ្នកសារព័ត៌មាននៅក្នុងតំបន់។ សៀវភៅរឿងអេឡិចត្រូនិកមួយក្បាលដែលមានចំណងជើងថា«ការបិទមាត់អ្នកនាំសារ៖ រឿងរ៉ាវនៃការវាយប្រហារអ្នកសារព័ត៌មានចំនួន ១០ រូបនៅអាស៊ីអាគ្នេយ៍» ដែលចងក្រងករណីសិក្សានានាពីតំបន់អាស៊ីអាគ្នេយ៍ ត្រូវបានផលិត និងដាក់ឱ្យប្រើដោយសម្ព័ន្ធភាពក្នុងតំបន់ដែលឃ្លាំមើលសេរីភាពសារព័ត៌មាននៅអាស៊ីអាគ្នេយ៍ ក្រោមការរៀបចំរបស់សម្ព័ន្ធអ្នកសារព័ត៌មានឯករាជ្យឥណ្ឌូនេស៊ី (AJI Indonesia) ក្នុងនោះ ក៏មានរឿងរ៉ាវលេចធ្លោរបស់អ្នកសារព័ត៌មានកម្ពុជាមួយរូបដែលសរសេរដោយខេមបូចាផងដែរ។ ការដាក់ឱ្យដំណើរការសៀវភៅនេះធ្វើឡើងនៅថ្ងៃទី ២៦ ខែវិច្ឆិកា តាមរយៈព្រឹត្តិការណ៍ចម្រុះដែលរៀបចំឡើងដោយ AJI Indonesia សហការជាមួយសម្ព័ន្ធភាពក្នុងតំបន់។

ក្នុងខែតុលា ឆ្នាំ ២០២៤ យើងបានអញ្ជើញក្រុមប្រឹក្សាសារព័ត៌មានទីម័រឡេស្តេ ដែលជាប្រធានបណ្តាញក្រុមប្រឹក្សាសារព័ត៌មានអាស៊ីអាគ្នេយ៍ (SEAPC-Net) មកចែករំលែកបទពិសោធន៍ល្អៗរបស់ពួកគេ ក្នុងការការពារសុវត្ថិភាព សន្តិសុខ និងការលើកកម្ពស់វិជ្ជាជីវៈប្រព័ន្ធផ្សព្វផ្សាយនៅក្នុងប្រទេសរបស់ពួកគេក្នុងកិច្ចប្រជុំកម្រិតខ្ពស់មួយ ដែលរៀបចំរួមគ្នាដោយខេមបូចា និងការិយាល័យអង្គការយូណេស្កូនៅភ្នំពេញ ដើម្បីប្រារព្ធទិវាអន្តរជាតិបញ្ចប់និទណ្ឌភាពចំពោះឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាន ដែលមានការគាំទ្រពីប្រទេសស៊ុយអែត និងស្ថានទូតអូស្ត្រាលី។ តាមរយៈវេទិកាជាតិយើងបានធ្វើការតស៊ូមតិឱ្យមានអង្គភាពឯករាជ្យសម្រាប់ត្រួតពិនិត្យវិស័យសារព័ត៌មានជំនួសឱ្យការគ្រប់គ្រងដោយរដ្ឋាភិបាល។




## ភាពជាដៃគូអន្តរជាតិ

ខេមបូចា ត្រូវបានគេចាត់ទុកជាមូលដ្ឋានយោងសំខាន់សម្រាប់អង្គការគាំទ្រប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ ពាក់ព័ន្ធនឹងទិន្នន័យសុវត្ថិភាពអ្នកសារព័ត៌មាន និងស្ថានភាពសេរីភាពសារព័ត៌មាននៅកម្ពុជា។ អង្គការនេះបានទទួលសំណើជាច្រើនសម្រាប់ផ្ទៀងផ្ទាត់ព័ត៌មាន និងការផ្តល់យោបល់អំពីបញ្ហាសុវត្ថិភាព និងសេរីភាពសារព័ត៌មានក្នុងប្រទេស។ ដៃគូអន្តរជាតិទាំងនោះរួមមាន សហព័ន្ធអ្នកសារព័ត៌មានអន្តរជាតិ (IFJ) អង្គការអ្នកការសែតគ្មានព្រំដែន(RSF) អង្គការគណៈកម្មាធិការការពារអ្នកសារព័ត៌មាន(CPJ) អង្គការគាំទ្រប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ (IMS) ជាដើម។

ខេមបូចា ក៏បានបង្កើតភាពជាដៃគូបច្ចេកទេសជាមួយ មជ្ឈមណ្ឌលសេរីភាពប្រព័ន្ធផ្សព្វផ្សាយ (CFOM) ដើម្បីពង្រឹងគុណភាពនៃការត្រួតពិនិត្យសុវត្ថិភាពអ្នកសារព័ត៌មាន។ ទោះបីគម្រោងជាមួយ CFOM បានបញ្ចប់នៅខែធ្នូកន្លងមក ក៏ដោយខេមបូចា នៅតែបន្តសហការជាមួយមជ្ឈមណ្ឌលនេះ ដើម្បីធានាថាវិធីសាស្ត្រត្រួតពិនិត្យថ្មីៗដែលបានសម្របតាមសូចនាករសុវត្ថិភាពអ្នកសារព័ត៌មាន (JSIs) របស់អង្គការយូណេស្កូ ត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាពក្នុងកម្រិតសមត្ថភាពបច្ចុប្បន្នយើង។

## វត្ថុបំណងទី៣៖ បង្កើនភាពអាចរកបាន និងលទ្ធភាពទទួលបានព័ត៌មានដែលអាចទុកចិត្តបានសម្រាប់អ្នកទស្សនា

មធ្យោបាយសំខាន់ៗចំនួនបួនដូចខាងក្រោម ត្រូវបានប្រើប្រាស់ដើម្បីផលិតព័ត៌មានដែលអាចជឿទុកចិត្តបាន ហើយសាធារណជនអាចចូលមើលបានតាមរយៈវេទិកាឌីជីថល។

- ទីមួយផ្នែកព័ត៌មានខេមបូចា បានបន្តតួនាទីដ៏លេចធ្លោរបស់ខ្លួនក្នុងការផលិតព័ត៌មានក្នុងទម្រង់ផ្សេងៗគ្នា ដូចជាអត្ថបទ និងវីដេអូ លើប្រធានបទជាច្រើនរួមមាន សិទ្ធិមនុស្ស នយោបាយ បរិស្ថាន សេដ្ឋកិច្ច ការអភិវឌ្ឍ បញ្ហាគណនេយ្យភាពសង្គម និងប្រធានបទគួរឱ្យចាប់អារម្មណ៍ផ្សេងទៀត។
- ទីពីរ ខេមបូចា បានផ្តល់ការណែនាំគោលការណ៍សរសេរនិងកែសម្រួលព័ត៌មាន និងផ្តល់ជាវេទិកាដល់អ្នកសារព័ត៌មានឯករាជ្យ និងអ្នកសារព័ត៌មានប្រជាពលរដ្ឋ ដើម្បីផលិត និងផ្សព្វផ្សាយមាតិកាដែលមានវិជ្ជាជីវៈ។
- ទីបី តាមរយៈកម្មវិធីអភិវឌ្ឍន៍សមត្ថភាពរបស់ខេមបូចា យើងបានចេញផ្សាយព័ត៌មានដែលផលិតដោយអ្នកសារព័ត៌មានកម្ពុជា ដែលបានឈ្នះមូលនិធិគាំទ្រខ្នាតតូច ដើម្បីផលិតព័ត៌មានដែលមានគុណភាពលើបញ្ហាដែលមិនសូវមានការរាយការណ៍ តាមរយៈការសម្របសម្រួលរបស់កម្មវិធីអភិវឌ្ឍន៍សមត្ថភាពនេះ។
- ចុងក្រោយ យើងបានបង្កើតភាពជាដៃគូជាមួយអង្គការដែលមានជំនាញផ្សេងទៀត ដើម្បីផលិតព័ត៌មានស៊ីជម្រៅ អត្ថបទស៊ើបអង្កេត និងអត្ថបទបែបវិចារកថាជាដើម។

សរុបមក បុគ្គលិកសារព័ត៌មាន និងអ្នកសារព័ត៌មានឯករាជ្យដែលជាសមាជិកនៃសមាគម បានផលិត និងផ្សព្វផ្សាយរឿងចំនួន ៧២២ (អត្ថបទព័ត៌មាន ៦៧០ វីដេអូ ៤៨ និងរូបភាពចំនួន ៤) ដោយលើសគោលដៅប្រចាំឆ្នាំចំនួន ៤៨៣ រឿង។ ព័ត៌មានភាគច្រើនមានទាំងភាសាខ្មែរ និងអង់គ្លេស ហើយត្រូវបានផ្សព្វផ្សាយនៅលើទំព័រហ្វេសប៊ុកភាសាខ្មែរ និងអង់គ្លេសនៃខេមបូចាព័ត៌មាន ដើម្បីបានទៅដល់ទស្សនិកជនកាន់តែច្រើនដែលតែងតែចូលមើលព័ត៌មានរបស់ពួកគេតាមរយៈហ្វេសប៊ុក។ បន្ថែមពីលើទំព័រហ្វេសប៊ុក ព័ត៌មានក៏ត្រូវបានចែកចាយតាមរយៈវេទិកាបណ្តាញសង្គមផ្សេងទៀតផងដែរ ដូចជា X (ពីមុន Twitter) Telegram និង YouTube ផងដែរ។ អ្នកសារព័ត៌មានឯករាជ្យយ៉ាងហោចណាស់ ២១ នាក់ ទទួលបានការគាំទ្រដើម្បីចូលរួមក្នុងការរាយការណ៍និងផ្សព្វផ្សាយព័ត៌មានរបស់ពួកគេនៅលើទំព័រព័ត៌មានខេមបូចា។ អ្នកសារព័ត៌មានឯករាជ្យបានរួមចំណែក ៤០% នៃព័ត៌មានសរុបដែលបានផលិត (២៨៥ ក្នុងចំណោម ៧២២ ព័ត៌មាន) ។ តាមរយៈឱកាសទាំងនេះ ពួកគេអាចបន្តអាជីពរបស់ពួកគេ និងបំភ្លឺលើបញ្ហាជាច្រើនដែលមិនសូវមានការរាយការណ៍នៅក្នុងប្រទេសកម្ពុជា។

**ទិន្នន័យវិភាគឆ្នាំ ២០២៤ សម្រាប់ខេមបូចា**

អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះ គឺទិន្នន័យវិភាគឆ្នាំ ២០២៤ សម្រាប់ខេមបូចា បង្ហាញថាចំនួនអ្នកប្រើប្រាស់/អ្នកតាមដាន/អ្នកដារ បានកើនឡើងនៅគ្រប់វេទិកាទាំងអស់។

**cambojanews.com**
កើនឡើងសរុប
៣៧%

**khmer.cambojanews.com**
កើនឡើងសរុប
២៦%

**camboja.net**
កើនឡើងសរុប
៣៨%

**Facebook CamboJA News (អង់គ្លេស)**
កើនឡើងសរុប
៩%

**Facebook CamboJA News (ខ្មែរ)**
កើនឡើងសរុប
១៦%

**Facebook CamboJA (សមាគម)**
កើនឡើងសរុប
៩%

**Telegram CamboJA News**
កើនឡើងសរុប
២៩%

**X CamboJA News**
កើនឡើងសរុប
១៩.៩%

## វត្ថុបំណងទី ៤៖ ការអភិវឌ្ឍ និងការគ្រប់គ្រងអង្គភាព

ដើម្បីទទួលបាននូវបរិមាណហិរញ្ញវត្ថុដែលត្រូវការ និងសម្របខ្លួនទៅនឹងការប្រែប្រួលបរិបទនៃការផ្តល់មូលនិធិ ខេមបូចាបានបង្កើតផែនការសកម្មភាពនិរន្តរភាពក្នុងឆ្នាំ២០២៤តាមរយៈការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ និងការវាយតម្លៃតម្រូវការអ្នកទស្សនា។

**កំណត់ប្រភពចំណូលចម្រុះ**

សេចក្តីព្រាងផែនការនិរន្តរភាព/អាជីវកម្ម ត្រូវបានបង្ហាញដល់អ្នកពាក់ព័ន្ធនៅខែធ្នូ ហើយមតិកែលម្អបានបញ្ចូលទៅក្នុងផែនការនេះ។ ដំបូន្មានសំខាន់ពីអ្នកផ្តល់ជំនួយ និងស្ថាប័នសារព័ត៌មាន ដែលមានបទពិសោធន៍ខាងនិរន្តរភាពអាជីវកម្ម គឺត្រូវបន្តពិសោធន៍ប្រភពចំណូលចម្រុះ ដើម្បីចៀសវាងការពឹងផ្អែកលើប្រភពចំណូលតែមួយ ឬពីរប្រភេទ។

ប្រភពចំណូលដូចខាងក្រោមត្រូវបានជ្រើសរើសសម្រាប់ការសាកល្បងក្នុងរយៈពេលខ្លី មធ្យម និងវែង។ ប្រភពចំណូលរយៈពេលខ្លីត្រូវបានចាត់ទុកថាជា «ឱកាសដែលងាយស្រួលចាប់យក» ទាំងតាមរយៈការរៀបចំទម្រង់ចំណូលដែលមានស្រាប់ឱ្យមានលក្ខណៈផ្លូវការ ឬតាមរយៈឱកាសដែលបានរកឃើញក្នុងពេលបង្កើតផែនការតាមរយៈលទ្ធផលនៃការស្ទង់មតិ និងតាមរយៈការចូលរួមជាមួយអ្នកពាក់ព័ន្ធ។ ចំណែកឯប្រភពចំណូលរយៈពេលមធ្យម និងរយៈពេលវែងវិញ ត្រូវបានកំណត់ថាត្រូវការការវិនិយោគ និងធនធានបន្ថែម ដែលបច្ចុប្បន្នមិនទាន់មាន ឬត្រូវការការសិក្សាស្រាវជ្រាវបន្ថែមទៀតដើម្បីវាយតម្លៃពីលទ្ធភាពនៃការអនុវត្ត។

## ការបង្កើនសមត្ថភាពសម្រាប់បុគ្គលិក និងអ្នកហាត់ការ

បុគ្គលិក និងអ្នកហាត់ការ ក៏បានទទួលវគ្គបណ្ដុះបណ្ដាលជាច្រើន ជុំវិញប្រធានបទដែលទាក់ទងនឹងការអភិវឌ្ឍន៍ស្ថាប័ន។ វគ្គបណ្ដុះបណ្ដាលទាំងនេះរួមមាន៖

- វគ្គបណ្ដុះបណ្ដាលរំឭកឡើងវិញពីហិរញ្ញវត្ថុ (បុគ្គលិកចំនួន ១៥នាក់, បុរស ៦នាក់, ស្ត្រី ៩នាក់)។
- ថ្ងៃទី ២០ ខែមិថុនា៖ សិក្ខាសាលាពិគ្រោះយោបល់ស្ដីពីសេចក្ដីព្រាងដំបូងនៃប្រព័ន្ធ MEAL (បុគ្គលិកចំនួន ១៦នាក់, បុរស ៦នាក់, ស្ត្រី ១០នាក់)
- ថ្ងៃទី ២៥ ខែមិថុនា៖ សិក្ខាសាលាពិគ្រោះយោបល់លើកទី១ ស្ដីពី យុទ្ធសាស្ត្រអាជីវកម្ម (ការកំណត់ប្រភពចំណូល) (បុគ្គលិក/កម្មសិក្សាការីចំនួន ២៦នាក់, បុរស ១៣នាក់, ស្ត្រី ១៣នាក់)
- ថ្ងៃទី១០ ខែកក្កដា៖ វគ្គបណ្ដុះបណ្ដាលផ្នែកច្បាប់លើកទី១ ស្ដីពីសិទ្ធិអ្នកសារព័ត៌មាន (បុគ្គលិក/អ្នកហាត់ការចំនួន ២០នាក់, បុរស ១១នាក់, ស្ត្រី ៩នាក់)
- ថ្ងៃទី ១២ ខែកក្កដា៖ វគ្គបណ្ដុះបណ្ដាលស្ដីពីសិទ្ធិការងារ និងពន្ធ (បុគ្គលិក/កម្មសិក្សាការីចំនួន ២០ នាក់)
- ថ្ងៃទី ២៦ ខែកក្កដា៖ សិក្ខាសាលាស្ដីពីការវាយតម្លៃហានិភ័យ សុវត្ថិភាពឌីជីថល និងការបង្កើតគោលនយោបាយព័ត៌មានវិទ្យា (បុគ្គលិក/កម្មសិក្សាការីចំនួន ២៧នាក់, បុរស ១៥នាក់, ស្ត្រី ១២នាក់)
- ថ្ងៃទី ០៦-០៧ ខែសីហា៖ វគ្គបណ្ដុះបណ្ដាលប្រព័ន្ធ MEAL (បុគ្គលិកចំនួន ១៨នាក់, បុរស ៧នាក់, ស្ត្រី ១១នាក់)
- ថ្ងៃទី ០៩ ខែកញ្ញា៖ វគ្គបណ្ដុះបណ្ដាលលើកទី២ ស្ដីពីសិទ្ធិអ្នកសារព័ត៌មាន (បុគ្គលិក/កម្មសិក្សាការីចំនួន ២៥នាក់, បុរស ១១នាក់, ស្ត្រី ១៤នាក់)
- ថ្ងៃទី ២៣ ខែធ្នូ៖ វគ្គបណ្ដុះបណ្ដាលស្ដីពីការចាត់ថ្នាក់ទិន្នន័យ (បុគ្គលិក/កម្មសិក្សាការីចំនួន ២៥ នាក់)
- វគ្គបណ្ដុះបណ្ដាលផ្សេងទៀតចំនួន ៣វគ្គ ស្ដីពីទាសភាពសម័យទំនើប ការយាយីផ្លូវភេទ និងការការពារកុមារ





# បញ្ហាប្រឈម

**ខេមបូចាបានប្រឈមមុខនឹងបញ្ហាជាច្រើនទាំងខាងក្រៅនិងខាងក្នុងស្ថាប័ន ខណៈដែលកំពុងអនុវត្តផែនការការងារប្រចាំឆ្នាំរបស់យើង។**

១ បរិយាកាសរឹតត្បិត និងការគំរាមកំហែងចំពោះសំឡេងឯករាជ្យ។

២ អ្នកសារព័ត៌មានឯករាជ្យមួយចំនួនមានការលំបាកក្នុងការបន្តបណ្ណសារព័ត៌មាន និងត្រូវបានអាជ្ញាធរសួរពីវិជ្ជាជីវៈរបស់ពួកគេ។

៣ កង្វះខាតអ្នកសារព័ត៌មានស្ត្រីក្នុងការចូលរួមវគ្គបណ្តុះបណ្តាល និងចូលជាសមាជិកសាខានៅថ្នាក់មូលដ្ឋាន។ វគ្គបណ្តុះបណ្តាលដែលផ្តោតលើអ្នករាយការណ៍ព័ត៌មាននៅតាមបណ្តាខេត្ត តែងតែទទួលបានអត្រាការចូលរួមជាស្ត្រីតិច (តិចជាង ២០%)។

៤ អ្នកសារព័ត៌មាននៅតែប្រឈមនឹងភាពលំបាកក្នុងការស្វែងរកប្រភពព័ត៌មាន និងទទួលបានព័ត៌មានផ្លូវការ ជាពិសេសពេលរាយការណ៍អំពីប្រធានបទសំខាន់ៗ ដូចជា អំពើពុករលួយ អភិបាលកិច្ច និងការជួញដូរមនុស្ស។

៥ ការផ្លាស់ប្តូរបរិបទនៃការផ្តល់មូលនិធិ មានផលប៉ះពាល់ខ្លះលើផែនការប្រតិបត្តិការ។

# មេរៀនដែលទទួលបាន

**ការស្វែងយល់ពីតម្រូវការរបស់អ្នកទស្សនាព័ត៌មានរបស់យើង**

ដើម្បីទទួលបានព័ត៌មានសម្រាប់ការអភិវឌ្ឍន៍ផែនការអាជីវកម្ម ទីប្រឹក្សាអភិវឌ្ឍន៍អង្គការរបស់ខេមបូចា បានសហការជាមួយផ្នែកព័ត៌មានក្នុងការធ្វើការស្ទង់មតិលើតម្រូវការអ្នកទស្សនាតាមអនឡាញកាលពីខែវិច្ឆិកា និងការពិភាក្សាក្រុមចំនួនពីរនៅពាក់កណ្ដាលខែធ្នូ ជាមួយអ្នកទស្សនាព័ត៌មានដែលបានជ្រើសរើស ដើម្បីកែលម្អយុទ្ធសាស្ត្រខ្លឹមសារព័ត៌មាន និងផែនការអាជីវកម្មរបស់ខេមបូចា។ ការស្ទង់មតិចំនួន ១៦៩ ត្រូវបានវិភាគដោយមានចំនួនមួយចំនួនត្រូវបានបោះចោលដោយសារតែមិនបានបំពេញគ្រប់ជ្រុងជ្រោយ។ ការពិភាក្សាក្រុមលើកដំបូងគឺតាមអនឡាញជាមួយអ្នកចូលរួមចំនួន ១០ នាក់ (ស្ត្រី ១ នាក់) មកពីបណ្ដាខេត្ត ហើយការពិភាក្សាមួយទៀតដោយផ្ទាល់ជាមួយអ្នកចូលរួមចំនួន ៩ នាក់ (ស្ត្រី ៣ នាក់) នៅភ្នំពេញ។

លទ្ធផលនៃការវិភាគបានបង្ហាញថា អ្នកអានភាគច្រើនជាបុរស មានអាយុចន្លោះពី ២៥ ទៅ ៤៤ ឆ្នាំ មានគ្រួសារមានបរិញ្ញាបត្រ និងកំពុងបម្រើការងារនៅក្នុងវិស័យអភិវឌ្ឍន៍នៅរាជធានីភ្នំពេញ។ ទាក់ទងនឹងការទទួលព័ត៌មានពួកគេភាគច្រើនចូលមើលព័ត៌មានជាច្រើនដងក្នុងមួយថ្ងៃ តាមរយៈទូរស័ព្ទដៃ ដោយច្រើនជាងគេគឺនៅចន្លោះម៉ោង ៦ ទៅ ៨ ព្រឹក ក្រៅពីនោះ គឺនៅពេលសម្រាកថ្ងៃត្រង់ ពេលរសៀល និងពេលល្ងាច។ ក្នុងចំណោមអ្នកឆ្លើយសំណួរ ៥២% កំពុង Subscribe ព័ត៌មានពីប្រភពណាមួយ ហើយជិត ២៥% មានបំណងចង់បង់ប្រាក់ ដើម្បីអានព័ត៌មាន តាមរយៈកាតឥណទាន ឬ QR Code។ ប្រធានបទដែលអ្នកអានចាប់អារម្មណ៍ជាងគេ តាមលំដាប់ គឺនយោបាយជាតិ សិទ្ធិមនុស្ស សេដ្ឋកិច្ចនិងធុរកិច្ច សេរីភាពសារព័ត៌មាន បរិស្ថាន និងការប្រែប្រួលអាកាសធាតុរីឯប្រធានបទសិទ្ធិការងារ និងព័ត៌មានអន្តរជាតិ ក៏ទទួលបានការចាប់អារម្មណ៍មិនចាញ់គ្នាដែរ។ ប្រភពព័ត៌មានចម្បងរបស់ពួកគេ គឺបណ្ដាញសង្គម បន្ទាប់មក គេហទំព័រព័ត៌មាន។ ហ្វេសប៊ុក (៨៣%) គឺជាបណ្ដាញសង្គមដែលពេញនិយមជាងគេ បន្ទាប់មកគឺ Telegram (៥០%) YouTube (៤៦%) និង Twitter/X (៣០%)។ លើសពីនេះ ៧០% នៃអ្នកឆ្លើយសំណួរយល់ថា ម៉ាកសញ្ញា (Brand) របស់ប្រភពព័ត៌មាន ពិតជាមានសារៈសំខាន់ក្នុងការកសាងទំនុកចិត្ត ខណៈ ៤៥% យល់ថា អ្នកសារព័ត៌មានផ្ទាល់ក៏សំខាន់ដូចគ្នាដែរ។ គួរឱ្យកត់សម្គាល់អ្នកឆ្លើយសំណួរភាគច្រើនបង្ហាញទំនុកចិត្តខ្ពស់ចំពោះព័ត៌មានខេមបូចា។ដោយផ្អែកលើគំរូនៃការចង់បានព័ត៌មានឃើញថា ៧២% នៃអ្នកឆ្លើយសំណួរចង់បានព័ត៌មានបែប «Update Me (ធ្វើបច្ចុប្បន្នភាពព័ត៌មានឱ្យខ្ញុំ)» បន្ទាប់មក «Give me perspective (ផ្ដល់ទស្សនវិស័យដល់ខ្ញុំ)» (៦៧%), «Keep me on trend/engaged (ធ្វើឱ្យខ្ញុំទាន់និន្នាការ/ចូលរួម)» (៤៧%), និង «Educate me (ផ្ដល់ចំណេះដឹងដល់ខ្ញុំ)»(៤៧%)។ ចំពោះទម្រង់នៃការផលិតព័ត៌មានវិញ គេឃើញថាអត្ថបទខ្លី វីដេអូ និងអត្ថបទវែង គឺជាជម្រើសដែលពេញនិយមជាងគេ។

បន្ទាប់មកលទ្ធផលទាំងនេះត្រូវបានបង្ហាញនៅក្នុងកិច្ចពិភាក្សាក្រុម ហើយសំណួរជាបន្តបន្ទាប់ក៏ត្រូវបានចោទសួរទៅកាន់អ្នកចូលរួមផងដែរ។ ជាទូទៅ ពួកគេបានឯកភាពទៅនឹងលទ្ធផលដែលបានរកឃើញ ជាពិសេសទាក់ទងនឹងចំណង់ចំណូលចិត្តក្នុងការទទួលព័ត៌មាន និងប្រភេទខ្លឹមសារ ហើយក៏បានផ្ដល់ជាអនុសាសន៍សំខាន់ៗមួយចំនួនដល់ខេមបូចាផងដែរ។ ក្រុមអ្នកចូលរួមមកពីបណ្ដាខេត្តបានលើកឡើងថា ដោយសារចំនួន

អ្នកអានមកពីខេត្តមានចំនួនតិច ខេមបូចាគួរតែបង្កើនការផ្សព្វផ្សាយគេហទំព័រព័ត៌មានរបស់ខ្លួនតាមរយៈវិទ្យុ និងអង្គការក្នុងស្រុក ព្រមទាំងផលិតព័ត៌មានទាក់ទងនឹងកសិកម្ម និងបញ្ហាផ្សេងៗដែលប្រជាជននៅតាមទីជនបទកំពុងព្រួយបារម្ភ។ រីឯក្រុមអ្នកចូលរួមនៅភ្នំពេញ ដែលភាគច្រើនជាយុវជន បានលើកយោបល់ថាខេមបូចាគួរតែផលិតព័ត៌មានដែលទាក់ទងនឹងចំណាប់អារម្មណ៍របស់យុវវ័យឱ្យបានច្រើនជាងមុន ព្រមទាំងស្នើឱ្យបង្កើនការផលិតវីដេអូ ឬកម្មវិធីជាសំឡេងសម្រាប់ចាក់ផ្សាយនៅពេលព្រឹក ការពិភាក្សាតុមូល និងផតខាសជាដើម។ ក្រុមអ្នកចូលរួមនៅភ្នំពេញក៏បានលើកជាគំនិតឱ្យបង្កើតកម្មវិធីទូរស័ព្ទ (App) សម្រាប់ព័ត៌មានខេមបូចាផងដែរ ដើម្បីធានាបាននូវភាពជាម្ចាស់កម្មសិទ្ធិលើប្រភពព័ត៌មាន។ គួរកត់សម្គាល់ថា សមាជិកក្រុមពិភាក្សាដែលជាយុវជននៅទីក្រុង មានអត្រាអ្នកជាវព័ត៌មាន និងមានឆន្ទៈក្នុងការចំណាយប្រាក់ដើម្បីអានព័ត៌មាន ខ្ពស់ជាងអ្នកចូលរួមមកពីខេត្ត។

**តួនាទីសំខាន់ៗរបស់អ្នកសារព័ត៌មានតាមបណ្តាខេត្ត និងបណ្តាញអ្នកសារព័ត៌មានស្ត្រី**

ដោយសារការយល់ដឹងកាន់តែស៊ីជម្រៅអំពីតម្រូវការរបស់អ្នកសារព័ត៌មាននៅតាមបណ្តាខេត្ត ខេមបូចាបានបន្តពង្រឹងសាខាថ្នាក់មូលដ្ឋានតាមតំបន់ទាំងពីរ ដែលបានបង្កើតឡើងនៅចុងឆ្នាំ ២០២៣ ក្នុងតំបន់ចំនួនពីរ ដែលគ្របដណ្តប់លើ ១០ ខេត្ត។ ការពង្រឹងនេះរួមមានការរៀបចំព្រឹត្តិការណ៍សិក្សា និងការកសាងបណ្តាញទំនាក់ទំនងជាប្រចាំ ទាំងតាមប្រព័ន្ធអនឡាញ និងដោយផ្ទាល់ ព្រមទាំងការសម្របសម្រួលការគាំទ្រផ្សេងៗទៀត ពីខេមបូចា និងអង្គការដៃគូ ដូចជា មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR), អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា, មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)ជាដើម។ លើសពីនេះ បណ្តាញអ្នកសារព័ត៌មានតាមខេត្ត (ដែលជាសាខាថ្នាក់មូលដ្ឋាន) ត្រូវបានលើកកម្ពស់សមត្ថភាពឱ្យដើរតួនាទីសកម្មក្នុងការតាមដានស្ថានការណ៍សារព័ត៌មាន និងសុវត្ថិភាពរបស់អ្នកសារព័ត៌មាននៅកម្រិតសហគមន៍។

យ៉ាងហោចណាស់មានករណីយាយីចំនួន៦ករណីប្រឆាំងនឹងអ្នកសារព័ត៌មានត្រូវបានរាយការណ៍ដោយសមាជិកសាខាថ្នាក់មូលដ្ឋាន ទៅកាន់ក្រុមការងារតាមដានឃ្លាំមើលរបស់ខេមបូចា សម្រាប់ការផ្ទៀងផ្ទាត់បន្ថែម។ ករណីទាំងនេះត្រូវបានផ្សព្វផ្សាយនៅលើទំព័រគេហទំព័រតស៊ូមតិរបស់ខេមបូចា ក៏ដូចជានៅលើគេហទំព័រសម្ព័ន្ធភាពត្រួតពិនិត្យសេរីភាពសារព័ត៌មានក្នុងតំបន់ ដែលត្រួតពិនិត្យ និងកសាងភស្តុតាងដោយផ្អែកលើការវាយប្រហារ និងការគំរាមកំហែងប្រឆាំងនឹងអ្នកសារព័ត៌មាន និងបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយនៅទូទាំងតំបន់អាស៊ីអាគ្នេយ៍។

- ការយាយីលើរូបរាងកាយលើអ្នកសារព័ត៌មានអំឡុងពេលរាយការណ៍ផ្ទាល់ពីគ្រោះថ្នាក់ចរាចរ
  (Journalist Physically Harassed During A Live Report Of A Traffic Accident)
- (អ្នកសារព័ត៌មានត្រូវបានប្ដឹងដោយសារតែរាយការណ៍អំពីល្បែងអនឡាញនៅក្នុងខេត្តឧត្តរមានជ័យ
  (Journalist Sued For Report On Online Gambling in Oddar Meanchey Province)
- [បច្ចុប្បន្នភាព] សាលាឧទ្ធរណ៍តំកល់ការផ្តន្ទាទោសអ្នកកាសែត
  [Update] (Appeal Court Upholds Conviction Against Journalist)

- អ្នកកាសែតនៅខេត្តរតនគីរីត្រូវបានឃុំខ្លួនរយៈពេលខ្លីបន្ទាប់ពីចូលទៅកាន់ទីតាំងអាជីវកម្មរ៉ែ [(Ratanakiri Journalist Briefly Detained After Entering A Plantation To Cover A Mining Activity)]
- អ្នកកាសែតនៅខេត្តមណ្ឌលគីរីត្រូវបានប្តឹងដោយមន្ត្រីប៉ូលីសព្រំដែនក្រោយពីរាយការណ៍អំពីការនាំចេញឈើបេងខុសច្បាប់ (Mondulkiri journalist sued by border police officer for reporting about illegal timber exports)
- អ្នកកាសែតនៅខេត្តសៀមរាបពីរនាក់ត្រូវបានវាយដំរូបរាងកាយដោយមន្ត្រីប៉េអឹម (Two Siem Reap Journalists Physically Assaulted by Military Police)

តាមរយៈកិច្ចសហការជាមួយបណ្ដាញអ្នកសារព័ត៌មានស្ត្រីកម្ពុជា (CFJ) ដើម្បីពង្រឹងភាពដឹកនាំក្នុងបណ្ដាញ យើងបានរកឃើញថា មានកម្រិតស្រេសផ្លូវចិត្តគួរឱ្យកត់សម្គាល់នៅក្នុងចំណោមសមាជិក CFJ ហើយសមាជិកទាំងនេះផ្តល់តម្លៃខ្ពស់ចំពោះបណ្ដាញនេះ។ លទ្ធផលនេះត្រូវបានបញ្ជាក់តាមការស្ទង់មតិសុខុមាលភាពក្នុងចំណោមសមាជិក CFJ ដែលបានធ្វើឡើងក្នុងឆ្នាំ ២០២៤។

**ការសម្របសម្រួលជាមួយអង្គការគាំទ្រប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក ដើម្បីធានាការឆ្លើយតបភ្លាម។**

យើងក៏បានដឹងផងដែរថា មានកង្វះខាតការសម្របសម្រួលក្នុងចំណោមអង្គការគាំទ្រប្រព័ន្ធផ្សព្វផ្សាយនៅក្នុងប្រទេស ដើម្បីដោះស្រាយបញ្ហាសុវត្ថិភាពរបស់អ្នកសារព័ត៌មាន ជាពិសេសការភ្ជាប់អ្នកសារព័ត៌មានដែលមានហានិភ័យទៅនឹងសេវាគាំទ្រទាន់ពេលវេលានិងមានប្រសិទ្ធភាព។ដូច្នេះខេមបូចាបានផ្តួចផ្តើមបង្កើតក្រុមការងារសុវត្ថិភាពអ្នកសារព័ត៌មាន ដែលមានអង្គការគាំទ្រប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក និងអង្គការសិទ្ធិមនុស្សចំនួនបី។ នៅក្នុងដំណាក់កាលដំបូង សមាជិកបានយល់ព្រមចាប់ផ្តើមក្រុមការងារនេះជាមួយអង្គការទាំងបីនេះតែប៉ុណ្ណោះ ដើម្បីធានាប្រសិទ្ធភាពនៃការសម្របសម្រួល និងស្វែងយល់បន្ថែមអំពីលទ្ធភាពនាពេលអនាគតក្នុងការចូលរួមជាមួយអង្គការផ្សេងទៀត ដែលមានសេវាគាំទ្រសម្រាប់អ្នកសារព័ត៌មាន ដើម្បីបង្កើនការប្រើប្រាស់ធនធានដែលមានឱ្យបានជាអតិបរមា៕

## ទំនាក់ទំនងមកកាន់យើង ៖


+៨៥៥ ២៣ ៨៨ ២៣ ១១

communications@camboja.net

អេសអេសភី អូហ្វីស ស្តេស ជាន់ទី៤(G) ផ្ទះលេខ៤៨
មហាវិថីសម្តេច ប៉ែន នុត (២៨៩) សង្កាត់បឹងកក់២
ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រទេសកម្ពុជា

www.camboja.net


លើកកម្ពស់សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលបានព័ត៌មាន